# រឿងអាឡាដាំង (Aladdin)
# ឬចង្កៀងទិព្វ
## (ភាគទី៣៩)

នៅក្នុងរាជធានីមួយ ដែលខ្ញុំចាំឈ្មោះពុំប្រាកដ នៃអាណាចក្រចិន ដែលជាអាណាចក្រធំទូលាយប្រកបដោយភោគទ្រព្យសម្បូរហូរហៀរ មានបុរសម្នាក់ឈ្មោះ មុស្តាហ្វា (Mustafa) គាត់រស់នៅដោយប្រកបការងារ ធ្វើជាជាងកាត់ខោអាវ ។ មុស្តាហ្វា ជាអ្នកក្រីក្រកម្សត់ទុគ៌តក្រៃលែង ។ កិច្ចការគាត់បានផ្តល់ផល ដ៏តិចតួចស្តួចស្តើងពេកណាស់ស្ទើរតែមិនគ្រប់គ្រាន់ចួនលម្ម នឹងចិញ្ចឹមមាត់គាត់ ប្រពន្ធនិងកូនគាត់ ដែលព្រះអាទិទេពបានផ្តល់ឱ្យនោះផង ។

កូនប្រុសគាត់ឈ្មោះអាឡាដាំង ជាក្មេងកើតឡើងខ្វះការអប់រំខ្វះហ្វឹកហាត់ពត់ចិត្ត ជាហេតុបណ្តាលឱ្យកុមាររេចិត្តតែទៅរកប្រព្រឹត្តអំពើអាក្រក់ជាកុមារកោងកាច ព្រហើនពានពារមិនខ្លាចឪពុកម្តាយ ។ លុះមានវ័យចម្រើនធំបន្តិចឡើងឪពុកម្តាយមិនអាចហាមឃាត់ ឬប្រដៅឱ្យកុមារនេះនៅផ្ទះបានឡើយ ។ តាំងពីព្រលឹមទល់ព្រលប់អាឡាដាំងតែងទៅរត់លេងនៅតាមផ្លូវ នៅកន្លែងសាធារណៈជាមួយនឹងក្មេងអនាថាឯទៀត ដែលមានវ័យខ្ចីជាងវាផង ។

លុះកុមារធំគ្រប់ការកាលណា ឪពុកដែលគ្មានវិជ្ជាអ្វីក្រៅពីវិជ្ជាខ្លួនចេះ ក៏បង្រៀនកូនឱ្យដេរ ។ ប៉ុន្តែទោះបុរសឪពុក ប្រើផ្លូវលួងលោម ឬកំហែងយ៉ាងណាក៏ពុំអាចញុំាងចិត្តកូនគាត់ឱ្យស្រឡាញ់ការងារនោះបានឡើយ ។ គឺថាឱ្យតែមុស្តាហ្វាបែរខ្នងភ្លែត អាឡាដាំងក៏គេចផ្លូចទៅលេងបាត់ទាល់ល្ងាច ។ ឃើញដូច្នេះ ឪពុកក៏បានធ្វើទណ្ឌកម្មជាញឹកញយ តែអាឡាំងជាក្មេងឥតកំណើត ចោលម្សៀតកែមិនឡើង ។ អស់ចំណេះនឹងកែគំនិតកុមារបាន បិតាក៏បណ្តោយតាមតែអំពើចិត្តវាទៅ ។ ការណ៍នេះធ្វើឱ្យមុស្តាហ្វា កើតទុក្ខប៉ុនភ្នំដោយពុំដឹងជារកមធ្យោបាយអ្វី ដើម្បីទាញបុត្រគាត់ឱ្យមកប្រកបការងារវិញបាន ក៏បណ្តាលទៅជាឈឺរ៉ាំរ៉ៃលុះត្រាតែក្ស័យជីវិតនៅពេលពីរបីខែបន្ទាប់ក្រោយមក ។

ពោលពីម្តាយអាឡាដាំងវិញ ដោយដឹងថាកូនខ្លួនមិនព្រមរៀនធ្វើការតាមរបរឪពុកហើយ ក៏ដាច់ចិត្តបិទទ្វារហាង លក់ឡាយឡុងប្រដាប់ប្រដាទាំងនោះឱ្យគេអស់ ដើម្បីយកលុយទុកចិញ្ចឹមជីវិត។ រួចគាត់ក៏ទៅរកស៊ីរវៃកប្បាសលក់ ។

ចាប់តាំងពីថ្ងៃដែលឪពុកវាអនិច្ចកម្មទៅ អាឡាដាំងទៅជាចៅហ្វាយលើខ្លួនឯង លែងស្តាប់បង្គាប់ម្តាយ ទៅជាបែរខ្នងគំហកគំរាមឱ្យម្តាយវិញ។ នៅពេលដែលគាត់និយាយទូន្មានបង្ហាញផ្លូវល្អ។ ពេលនោះ កុមារក៏តាំងតែប្រព្រឹត្តអំពើអបាយមុខពេញធឹងតែម្តង គឺ



ដើរលេងអាវ៉ាសែជាមួយនឹងក្មេងឯទៀត ដែលមានវ័យប្រហែលគ្នា គ្មានឈប់គ្មានបង្អង់សោះ មានតែរឹតតែរីកចិត្តរីកថ្លើមខ្លាំងឡើងៗលើសមុនទៀត ។ វាបានរស់នៅរបៀបនេះរហូតដល់អាយុ១៥ឆ្នាំ គ្មានផ្លាស់គំនិតថ្មី គ្មានគិតដល់វាសនាខ្លួនទៅអនាគតបន្តិចបន្តួចឡើយ ។ ថ្ងៃមួយនៅពេល ដែលវាកំពុងតែលេងជាធម្មតាជាមួយ នឹងពួកក្មេងប៉ាឡែងទៀត មានបរជនម្នាក់ដើរមកត្រង់កន្លែងនោះ ឈប់ឈរមើលវា ។

ជនចម្លែកនេះ ជាមេធ្មប់មួយយ៉ាងពូកែ ដែលអ្នកនិពន្ធរឿងនេះបានឱ្យឈ្មោះថា មេធ្មប់អាហ្វ្រិកាំង យើងហ៊ានហៅដូច្នេះ ព្រោះឃើញគាត់ទើបនឹងមកពីទ្វីបអាហ្វ្រិកចំនួនពីរថ្ងៃប៉ុណ្ណោះមែន ។

ដោយមេធ្មប់ ជាអ្នកចេះមើលទឹកមុខមនុស្ស គាត់ក៏សង្កេតមើលមុខអាឡាដាំង និងហេតុភេទសព្វគ្រប់ទៅ ស្គាល់ចរិយាគំនិតស្គាល់រហូតដល់ពូជពង្សវង្សាតារ ។ លុះពិនិត្យមើលកុមារកំព្រាឥតឪពុកសព្វគ្រប់ហើយ មេធ្មប់ក៏ដើរទៅជិតកុមារ ដឹកដៃចេញចម្ងាយពីរបីជំហាន ពីកុមារឯទៀតរួចសួរថា : “នែកូនប្រុស ! ឪពុកអ្នក ឬដែលឈ្មោះមុស្តាហ្វា ធ្វើជាជាងកាត់ដេរខោអាវ?” យុវជនក៏ឆ្លើយថា : “បាទ ! គឺឪពុកខ្ញុំហើយ តែគាត់អនិច្ចកម្មយូរយារណាស់ទៅហើយ” ។

ឮតែប៉ុណ្ណោះ មេធ្មប់អាហ្វ្រិកាំងក៏ស្ទុះទៅឱបរឹតថើបអាឡា-

ដាំង ហើយហូរទឹកភ្នែកច្រោកៗ ថែមទាំងដកដង្ហើមលាន់ឮរៗផង ។ អាឡាដាំងឃើញដូច្នេះក៏សួរថា : តើមានរឿងហេតុអ្វីបានជាលោកយំសោកដូច្នេះ? មេធ្មប់ក៏ឆ្លើយថា : "កូនប្រុសអើយ ! តើឱ្យខ្ញុំអត់ទ្រាំពុំចេញទឹកភ្នែកម្តេចបាន ខ្ញុំនេះហើយជាមាឯងបង្កើត ឯឪពុកឯងគឺបងពូនេះឯង ។ ជាយូរឆ្នាំណាស់មកហើយ មាបានដើរចោលស្រុក ។ ក្នុងថ្ងៃនេះ មាននឹកសង្ឃឹមថា បានជួបមុខគាត់ ហើយគាត់ក៏បានសប្បាយចិត្តដែរ ដោយសារបានឃើញមុខមា ស្រាប់តែឮក្មួយឯងនិយាយថា គាត់ស្លាប់បាត់ទៅហើយ ។ ឱ !ក្មួយអភ័ព្វអត់ឪពុក ! ទុក្ខមាពេលនេះធំណាស់ ព្រោះមាគ្មាននរណាជាទីពឹងពាក់សំណាក់អាស្រ័យឡើយ មាត្រូវរស់នៅតែឯកា ។ ប៉ុន្តែមាបានធូរទ្រូងបន្តិចទៅវិញ ដោយសារមាបានឃើញមុខក្មួយឯង ព្រោះថាកាលណាមានឹកទៅខ្មោចឪពុកឯង មាតែងនឹកមកក្មួយឯងមួយរំពេច ។ ហើយមាយល់ច្បាស់ថា មាឥតភ័ន្តច្រឡំឡើយ នៅពេលដែលមានិយាយទៅកាន់ក្មួយឯង ។ ពោលដូច្នេះហើយ មេធ្មប់អាហ្វ្រិកាំងក៏លូកដៃទៅក្នុងថង់យាមគាត់ យកប្រាក់រាយៗ មួយដៃធំឱ្យទៅអាឡាដាំងហើយពោលថា : "នែក្មួយប្រុស ! សូមក្មួយឯងត្រឡប់ទៅផ្ទះម្តាយឯងវិញទៅ ហើយនិយាយប្រាប់គាត់ថា មាផ្តាំឱ្យសួរសុខទុក្ខផង។ ស្អែកបើសិនជាមានឱកាស មានឹងទៅលេង ដើម្បីមើលទីកន្លែង ដែលឪពុកឯងកើត នឹងទីកន្លែងដែលគាត់ចាកចោលភពនេះ ។



ក្រោយពេល ដែលមេធ្មប់អាហ្វ្រិកាំងបង្គាប់ឱ្យអាឡាដាំងត្រឡប់ទៅផ្ទះវិញ អាឡាដាំងក៏ស្ទុះរត់សំដៅទៅផ្ទះ អរកខិបកខុបដោយបានលុយ ។ ទៅដល់ផ្ទះភ្លាម កុមារកំព្រាឥតឪពុក ក៏និយាយទៅកាន់ម្តាយថា : "ម៉ាក់ ! ម៉ាក់ ! ខ្ញុំមានមាទេម៉ាក់?" គ្មានទេកូនប្រុសម្តាយ សាច់ញាតិខាងខ្មោចឪពុកឯងក៏គ្មាន សាច់ញាតិខាងម្តាយក៏គ្មានដែរ ។ ម៉េចក៏ម៉ាក់មានប្រសាសន៍ដូច្នេះ កូនទើបតែជួបពូម្នាក់គាត់និយាយប្រាប់ខ្ញុំថា គាត់ត្រូវជាមាខ្ញុំ ត្រូវជាប្អូនប៉ាបង្កើត ។ ហើយលុះខ្ញុំជម្រាបប្រាប់គាត់ថា ប៉ាស្លាប់បាត់ទៅហើយ ។ គាត់ក៏ស្ទុះមកឱបខ្ញុំ យំស្រែកជាខ្លាំង ។ ដើម្បីជាបន្ទាល់ក្នុងរឿងនេះ កុមារក៏ដកលុយដែលមេធ្មប់នោះឱ្យបង្ហាញទៅម្តាយមើល ដោយពោលថា: ម៉ាក់មើលគាត់បានទាំងឱ្យលុយខ្ញុំទៀត ។ មិនតែប៉ុណ្ណោះគាត់ថែមទាំងផ្តាំផ្តានឹងខ្ញុំថា ឱ្យខ្ញុំជម្រាបសួរម៉ាក់ជូសគាត់ផង ។ ថ្ងៃស្អែកបើសិនជាមានពេលទំនេរ គាត់នឹងមកជម្រាបសួរម៉ាក់ផ្ទាល់ខ្លួនគាត់តែម្តង ដើម្បីមើលទីកន្លែងលំនៅប៉ាកើតនឹងកន្លែងប៉ាអស់សង្ខារ ។

- "នែកូនប្រុសម្តាយ ! ប៉ាឯងមានប្អូនប្រុសម្នាក់មែន តែគាត់ស្លាប់បាត់យូរយារណាស់ទៅហើយ ។ ហើយម៉ាក់ពុំដែលឮប៉ាឯងនិយាយថា មានបងប្អូនឯណាទៀតសោះ" ពោលតែប៉ុណ្ណោះម្តាយនឹងកូនក៏ឈប់ស្ងៀមទៅ ។

ស្អែកឡើង មេធ្មប់នោះក៏ទៅជួបនឹងអាឡាដាំង នៅកន្លែង

ផ្សេងទៀត ដែលអាឡាដាំងទៅលេងសប្បាយជាមួយនឹងគូកនវា ។ ជួបអាឡាដាំងកាលណា គាត់ក៏ឱបរឹតដូចពីមុន រួចឱ្យលុយមាសពីរដុំ ហើយនិយាយប្រាប់អាឡាដាំងថា “ក្មួយឯងយកលុយនេះទៅជូនម្ដាយឯង ហើយជម្រាបគាត់ថា ល្ងាចពូទៅលេង ឱ្យគាត់រកទិញអីវ៉ាន់ធ្វើម្ហូបសម្រាប់ពេលបាយល្ងាច ដើម្បីយើងបរិភោគជាមួយគ្នាសប្បាយ ។ ប៉ុន្តែក្មួយឯងប្រាប់មាផង តើឱ្យមាធ្វើដូចម្ដេច ដើម្បីរកផ្ទះក្មួយឯងឃើញ? អាឡាដាំងក៏និយាយប្រាប់សព្វគ្រប់រួចមេធ្មប់អាហ្វ្រិកាំងក៏ដើរចេញទៅ” ។

អាឡាដាំងក៏យកលុយនោះទៅជូនម្ដាយៗ លុះបានស្ដាប់កុមារនិយាយប្រាប់សព្វគ្រប់ អំពីសេចក្ដីប្រាថ្នានៃឪពុកមា ក៏ចេញទៅផ្សារទិញបានអីវ៉ាន់ជាច្រើនមុខហើយល្អៗផង ។ បន្ទាប់មក ដោយគាត់គ្មានចានក្បានល្អៗសម្រាប់ប្រើការ គាត់ក៏ទៅខ្ចីគេផ្ទះជិតខាង ។ ម្ដាយអាឡាដាំង ក្នុងថ្ងៃនេះគ្មានរវល់អ្វីក្រៅអំពីរៀបចំធ្វើម្ហូបអាហារឡើយ ។ លុះចម្អិនម្ហូបចំណីរួច ពេលក៏ល្ងាចល្មម នាងមេម៉ាយក៏និយាយទៅកាន់កូនគាត់ថា “កូនប្រុសម្ដាយ ! មាឯងប្រហែលជារកផ្ទះយើងពុំឃើញទេ ហេតុនេះចូរកូនឯងចេញទៅខាងក្រៅចាំមើលគាត់ បើឃើញកូនឯងនាំគាត់មក ។ ពិតមែនតែអាឡាដាំងបាននិយាយប្រាប់ទីលំនៅឪពុកខ្លួនប្រាប់ទៅមេធ្មប់សព្វគ្រប់ហើយ ក៏កុមារនៅតែរៀបចំខ្លួនចេញទៅចាំគាត់តាមបង្គាប់ម្ដាយ ពេលនោះស្រាប់តែឮសូរមនុស្ស



គោះទ្វារ ។ កុមារឮហើយស្ទុះទៅបើក ស្គាល់ច្បាស់ជាមេធ្មប់អាហ្វ្រិ-កាំងកំពុងតែដើរចូលមក ដៃកាន់ដបស្រានឹងផ្លែឈើគ្រប់យ៉ាងយកមកសម្រាប់បរិភោគល្ងាចនេះ ។

ក្រោយពេលដែលមេធ្មប់បានប្រគល់របស់ទាំងអស់នេះឱ្យអា-ឡាដាំងហើយ គាត់ក៏ចូលទៅជម្រាបសួរម្ដាយកុមារ រួចនិយាយសូមឱ្យគាត់បង្ហាញកន្លែងដែលមុស្តាហ្វាធ្លាប់អង្គុយនៅលើកៅអីវែង នាងមេម៉ាយក៏ចង្អុលប្រាប់សព្វគ្រប់ ។ មេធ្មប់នោះ ក៏លុតជង្គង់ឱនថើបកន្លែងនោះជាច្រើនដង ហើយយំស្រែករៀបរាប់ថា “ឱបងសម្លាញ់ ! ប្អូនចំជាអភ័ព្វមែន ដោយពុំបានឃើញមុខបងម្ដងទៀត មុនពេលដែលបងចាកចេញពីពិភពលោកយើងនេះទៅ” ។ ទោះបីម្ដាយអាឡាដាំងនិយាយអង្វរឱ្យអង្គុយលើកន្លែងនោះទៅ ក៏គាត់ពុំព្រមអង្គុយលើកន្លែងដដែលឡើយ ។ គាត់បែរជាឆ្លើយឡើងថា “ខ្ញុំមុខជាអង្គុយទល់មុខនិងកន្លែងនេះសិនព្រោះថា បើទុកជាខ្ញុំមិនបានឃើញគាត់នៅរស់នៅឡើយ ធ្វើជាឪពុកនៃគ្រួសារ ក៏ខ្ញុំសន្និដ្ឋានថា បានឃើញគាត់នៅនឹងមុខនេះដែរ” ។ ម្ដាយអាឡាដាំងក៏ឥតបង្ខំចិត្តមេធ្មប់នោះឡើយ បើកសេរីភាពឱ្យគាត់ក្នុងការជ្រើសរើសកន្លែងអង្គុយតាមចំណង់ ។

មេធ្មប់អាហ្វ្រិកាំង លុះរកកន្លែងអង្គុយបានគាប់ចិត្តហើយ ក៏ចាប់ជជែកបែកសាជាមួយម្ដាយអាឡាដាំងថា : “បង ! បងឯងកុំឆ្ងល់ឱ្យសោះ ដោយពុំបានឃើញមុខខ្ញុំតាំងពីបងរៀបការជាមួយនឹង

មុស្តាហ្វាបងប្រុសខ្ញុំនោះមក ព្រោះខ្ញុំដើរចោលស្រុកកំណើតខ្ញុំនេះអស់វារៈ៤០ឆ្នាំ ។ ចាប់តាំងពីថ្ងៃដែលខ្ញុំចេញពីមាតុភូមិនេះទៅក្រោយពេលដែលខ្ញុំបានធ្វើដំណើរ ទៅកាន់ប្រទេសឥណ្ឌាពែរ្ស៍ (Perse) អារ៉ាប៊ី, ស៊ីរី, អេហ្ស៊ីប ហើយបានសំណាក់នៅក្នុងទីក្រុងល្អៗនៃប្រទេសនោះ ខ្ញុំក៏បានចូលទៅនៅក្នុងទ្វីបអាហ្វ្រិកអស់ពេលយូរជាងគេ ។ ប៉ុន្តែជាធម្មតារបស់មនុស្សលោកនរណាក៏ដោយ បងអើយ ទោះឃ្លាតចេញពីស្រុកកំណើតទៅចម្ងាយណាក៏ដោយ ក៏ពុំអាចភ្លេចស្រុកកំណើត ភ្លេចឪពុកម្ដាយ ភ្លេចបងប្អូនភ្លេចញាតិមិត្តជិតឆ្ងាយបានឡើយ ។ ហេតុនេះ បានជាថ្ងៃមួយខ្ញុំកើតចិត្តត្រឡប់មកស្រុកកំណើតវិញទាន់ខ្ញុំនៅមានកម្លាំង មានសេចក្ដីក្លាហានក្នុងការធ្វើដំណើរ ដើម្បីបានមកឱបរឹតសួរសុខទុក្ខបងស្នេហ៍របស់ខ្ញុំ ។ ពេលនោះខ្ញុំក៏រៀបចំអីវ៉ាន់ វេចដាក់សំពាយរៀបដំណើរចេញមកភ្លាម ។ ឱបងអើយ ! ខ្ញុំពុំបាច់ជម្រាបទេ អំពីចម្ងាយផ្លូវដែលខ្ញុំត្រូវដើរ អំពីឧបសគ្គផ្សេងៗដែលខ្ញុំជួបប្រទះនៅតាមផ្លូវ និងសេចក្ដីហត់នឿយជាពន់ប្រមាណទំរាំតែមកដល់កន្លែងនេះទេ ព្រោះការនេះ គ្រាន់តែជាការបន្ទាប់បន្សំប៉ុណ្ណេះ។ ទុក្ខសោករបស់ខ្ញុំដែលធំជាងគេក្នុងលោកគឺទុក្ខក្រោយដែលបានឮដំណឹងថា បងសម្លាញ់របស់ខ្ញុំត្រូវស្ដេចមច្ចុរាជផ្ដួលផ្ដាច់ជីវិតទៅហើយ ។ តាំងពីពេលនោះ ខ្ញុំចេះតែសង្កេតឃើញទ្រង់ទ្រាយមុខមាត់ គាត់ហាក់ដូចគ្នាបេះបិទនឹងមុខក្មួយគាត់ ហើយបានធ្វើឱ្យខ្ញុំ



សម្គាល់ឃើញខុសពីក្មេងដទៃទៀត ។ កុមារនេះ ចេះនិយាយប្រាប់បងថា កាលបើខ្ញុំបានទទួលដំណឹងអាក្រក់អបមង្គលចង្រៃរោរពនេះហើយៗ តើខ្ញុំមានអាការៈយ៉ាងណាខ្លះ ។ ប៉ុន្តែយើងត្រូវនឹកគុណដល់ព្រះអាទិទេពផងចំពោះរឿងនេះ ។ ឥឡូវនេះ ខ្ញុំបានរំសាយទុក្ខបន្តិចដោយបានឃើញរូបកុមារនេះមានមុខមាត់រាងរៅ ដូចជាបងមុស្តាហ្វាខ្ញុំដែរ » ។

មេធ្មប់អាហ្វ្រិកាំង, លុះឃើញពពកខ្មៅគឺសេចក្ដីសោកសង្រេងគ្របសង្កត់លើម្ដាយអាឡាដាំងខ្លាំងពេក ព្រោះតែគាត់នាំរលឹករឿងខ្មោចប្ដីគាត់ក៏ឈប់និយាយពីរឿងនេះទៅ ហើយបែរជានិយាយទៅសួរឈ្មោះអាឡាដាំងម្ដងវិញ ។ អាឡាដាំងក៏ឆ្លើយថា ខ្ញុំឈ្មោះអាឡាដាំង ។ មេធ្មប់ក៏សួរទៀតថា អើចុះអាឡាដាំងឯងសព្វថ្ងៃរកស៊ីធ្វើការអ្វី ចេះមុខរបរអ្វីទេ ។

សំនួរនេះ បានធ្វើឱ្យអាឡាដាំងដាក់មុខជ្រប់ ភាំងស្មារតីរង្វេងស៊ុងអស់ ហាក់ដូចជាគេបាញ់ត្រូវនឹងគ្រាប់អាវុធអ្វីមួយ ។ ប៉ុន្តែពេលនោះ ម្ដាយអាឡាដាំងក៏ឆ្លើយជួសឡើងភ្លាមថា “អាឡាដាំងជាមនុស្សប៉ោឡែអនាថា គ្មានរបររកស៊ីអ្វីទេ” ។ ឪពុកវាកាលនៅរស់បានខំខ្នះខ្នែងប្រឹងប្រែងជាទីបំផុត ដើម្បីបង្រៀនកូនឱ្យចេះរកស៊ី, ប៉ុន្តែចាញ់ចំណេះ គាត់ពុំអាចពត់វាកើត ។ ចាប់តាំងពីថ្ងៃដែលគាត់អនិច្ចកម្មទៅ, ទោះជាខ្ញុំនិយាយដាស់តឿនវាម្ដងហើយម្ដងទៀតរោយមាត់

ស្ទើរទំពាបាយពុំកើតយ៉ាងណាក៏ដោយហើយជារាល់ថ្ងៃផង ក៏វាគ្មានទទួលត្រាប់ត្រង យកពាក្យប្រដៅអ្វីមួយម៉ាត់ ក្រៅពីធ្វើអំពើពុតពាលហើយនឹងចំណាយពេលដើរលេងអាវ៉ាសែជាមួយនឹងក្មេងឯទៀតៗ ដូចលោកប្អូនបានឃើញស្រាប់ គ្មានគិតថាខ្លួនវាធំពេញកំលោះធ្វើប្តីគេកើតហើយនោះទេ ។ ហើយពេលនេះ បើសិនជាប្អូនមិនជួយធ្វើឱ្យវាខ្លាសអំពើលាមកនេះទេ, ហើយបើវានៅតែប្រព្រឹត្តដូច្នេះទៀត, បងអស់សង្ឃឹមថា វានេះបានទៅជាក្បាលខ្សែអ្វីហើយ ។ ខ្លួនវាក៏ដឹងស្រាប់ហើយថា ឪពុកវាស្លាប់ទៅគ្មានសល់ទ្រព្យសម្បត្តិអ្វីទេ ហើយសព្វថ្ងៃ ខ្ញុំរកស៊ីតែរវៃកប្បាសលក់ដោយវេទនាជាក្រៃលែង ស្ទើរតែរកនំប័ុងទទួលទានពុំបាន ។ ចំណែកខ្ញុំៗបានគិតជាស្រេចហើយថា ថ្ងៃណាមួយខ្ញុំឈប់រកស៊ីចិញ្ចឹមវាទៀត ទុកឱ្យវាដើររកន្លែងផ្សេងនៅទៀតចុះ ។

ក្រោយពេលដែលម្តាយអាឡាដាំង មានប្រសាសន៍ទាំងទឹកភ្នែក ទឹកសំបោរដូច្នេះចប់កាលណា, មេធ្មប់អាហ្វ្រិកាំង ក៏និយាយទៅកាន់អាឡាដាំងថា "នែក្មួយពូ ធ្វើដូច្នេះមិនមែនឈ្មោះថាកុលបុត្រប្រសើរទេ ត្រូវឯងគិតអាណិតខ្លួនឯង អាណិតម្តាយ ត្រូវឯងគិតដូចម្តេចដើម្បីចិញ្ចឹមខ្លួនឯងឱ្យរស់ ។ របររកស៊ីមានច្រើនណាស់ បើឯងមិនពេញចិត្តមួយនេះ ត្រូវរើសរកមួយនោះ មើលទៅប្រហែលជារបរដែលឪពុកឯងធ្លាប់ធ្វើនោះមិនពេញចិត្តឯងទេ ដូច្នេះមានតែឯងពេញ



ចិត្តរបរផ្សេងទៀត ។ ចូរឯងកុំលាក់នឹងមាឱ្យសោះ ដែលមានិយាយនេះ គឺមាចង់ជួយឯងឱ្យចម្រើនទេតើ" ។ មេធ្មប់អាហ្វ្រិកាំង លុះមិនឮអាឡាដាំងឆ្លើយតបដូចម្តេច ក៏ពោលឡើងទៀតថា "បើឯងទាល់គំនិតពុំដឹងរកស៊ីធ្វើអ្វី តែឯងចង់ធ្វើខ្លួនឱ្យទៅជាមនុស្សត្រឹមត្រូវនឹងគេដែរនោះ។ មានឹងបើកហាងលក់កំណាត់មួយ ឱ្យឯងចាំតែអង្គុយលក់ចុះ។ ហើយប្រាក់ដែលបានចំណេញ មកពីកំណាត់នេះត្រូវឯងយកទៅទិញអីវ៉ាន់ផ្សេងៗមកលក់ទៀត ។ ធ្វើរបៀបនេះ ឯងនឹងអាចរស់នៅបានដោយថ្លៃថ្នូរ ។ ចូរឯងគិតរំពឹងមើលឱ្យមែនទែន ហើយនិយាយប្រាប់មាឱ្យត្រង់មក តើឯងគិតឃើញដូចម្តេច ។ ចំណែកមាៗប្រកាន់ពាក្យសន្យាជាដរាប ។

របរនេះបានធ្វើឱ្យអាឡាដាំងសប្បាយជាពន់ពេក ព្រោះបុរសនេះស្អប់ខ្ពើមការហត្ថកម្មណាស់ ហើយយល់ថាហាងលក់ទំនិញបែបដូច្នេះមុខជានឹងស្អាត ហើយមានមនុស្សមកទិញដូរច្រើនផង ។ ឯអ្នកម្ចាស់ហាងទៀតសោត ក៏ស្លៀកពាក់យ៉ាងស្អាតៗ ហើយជាមនុស្សមានមុខមាត់ផង ។ ដូច្នេះ អាឡាដាំងក៏ជម្រាបទៅមេធ្មប់អាហ្វ្រិកាំងដែលវាសម្គាល់ថាជាមាវាមែននោះថា វាចូលចិត្តប្រកបរបរនេះជាងរបរឯទៀតទាំងអស់ ហើយរបរនេះអាចធ្វើឱ្យវាបានទទួលទ្រព្យសម្បត្តិជាច្រើន ដើម្បីរស់នៅអស់មួយជីវិត ។ មេធ្មប់អាហ្វ្រិកាំងក៏ឆ្លើយឡើងថា "អើបើរបរនេះពេញចិត្តឯង, ស្អែកមានឹងនាំឯងទៅជាមួយ,

ហើយទិញសំលៀកបំពាក់ស្អាត១ ហើយថ្លៃផង ឱ្យឯងស្លៀក ដើម្បីសមជាមហាពាណិជក្នុងក្រុងនេះ ។ រួចដល់ថ្ងៃស្អែកមានឹងរៀបចំបើកហាងមួយ មានទំនងដូចមាបាននិយាយពីមុន" ។

និយាយពីម្តាយអាឡាដាំងវិញ ដែលតាំងតែពីដើមរៀងមកគាត់ឥតជឿថា មេធ្មប់អាហ្វ្រិកាំងត្រូវជាប្អូនប្តីគាត់សោះ, ឥឡូវនេះគាត់លែងសង្ស័យអ្វីទៀតហើយ ដោយឃើញបុរសនេះសន្យាថានឹងជួយរកទ្រព្យសម្បត្តិឱ្យកូនគាត់ទាល់តែបានសម្រេច ។ មិនតែប៉ុណ្ណោះគាត់ថែមទាំងទទួលអរគុណនឹងបំណងដ៏ប្រសើររបស់មេធ្មប់ទៀតផង ។ បន្ទាប់មក ក្រោយដែលគាត់បានក្រើនរំលឹកអាឡាដាំងឱ្យធ្វើខ្លួនឱ្យថ្លៃថ្នូរ ដើម្បីថែរក្សាទ្រព្យសម្បត្តិដែលមាជួយផ្តើមគំនិតរកឱ្យនេះ, ម្តាយអាឡាដាំងក៏លើកស្តុកបាយមក ។ ការជជែកគ្នាពីរឿងដដែលនេះក៏ប្រព្រឹត្តទៅក្នុងបរិយាកាសដ៏សែនរីករាយ លុះត្រាតែមេធ្មប់ជម្រាបលាម្តាយអាឡាដាំងនឹងអាឡាដាំងចេញទៅទើបចប់, ដោយយប់កាន់តែជ្រៅណាស់ទៅហើយ ។

លុះព្រឹកស្អែកឡើង, មេធ្មប់អាហ្វ្រិកាំងក៏បានមកដល់ផ្ទះនាងមេម៉ាយមុស្តាហ្វាដូចគាត់សន្យាមែន ។ គាត់ដឹកដៃអាឡាដាំងដើរតម្រង់ទៅផ្ទះមហាពាណិជមួយ ដែលមានលក់សុទ្ធតែខោអាវកាត់ស្រេចគ្រប់ធុនគ្រប់ពណ៌ ហើយតម្រូវទៅតាមអាយុ ឋានៈមនុស្សទៀត ។ មេធ្មប់ក៏យកខោអាវមករើសឱ្យសមទៅតាមទំហំខ្លួនអាឡា-



ដាំង, សម្លៀកបំពាក់ណាដែលគាត់ពេញចិត្ត គាត់ក៏ទុកទៅមួយកន្លែង សម្លៀកបំពាក់ណាដែលគាត់ពុំពេញចិត្ត គាត់ដាក់ទៅមួយកន្លែង, រួចគាត់និយាយទៅអាឡាដាំងថា "ក្មួយពូ ! ចូរក្មួយឯងរើសមើលបណ្តាសម្លៀកបំពាក់ទាំងអស់នេះ សម្លៀកបំពាក់ណាដែលក្មួយឯងពេញចិត្តជាងគេ សូមក្មួយឯងយកទៅ" ។ អាឡាដាំងត្រេកអរស្ទើរចង់ហោះ វាលោតកញ្ឆេងរិះតែរបូតខោពីចង្កេះលេច... ពុំដឹងខ្លួន ។ ដោយឃើញឪពុកមាបើកសេរីភាពឱ្យខ្លួនរើស សម្លៀកបំពាក់តាមចិត្តដូច្នេះ ។ បន្ទាប់មកវាក៏លូកដៃរើសយកខោអាវមួយប្រដាប់ភ្លាម ។ មេធ្មប់ក៏ទិញរបស់ឯទៀត១ជាច្រើន ដែលសម្រាប់លម្អសម្លៀកបំពាក់នោះ រួចក៏ចេញលុយឱ្យទៅម្ចាស់ហាងដោយឥតតថ្លៃមួយម៉ាត់ឡើយ ។

អាឡាដាំងលុះសម្លឹងមើលខ្លួនឯងឃើញល្អឆើតឆាយ តាំងពីក្បាលរហូតដល់ចុងជើង, ក៏ថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះលោកមេធ្មប់១ ក៏ពោលបន្ថែមទៀតថា មានឹងមិនបោះបង់ចោលក្មួយឯងទេមាសន្យាថានឹងនៅមួយក្មួយឯងជាដរាប ។ ពេលនោះមេធ្មប់អាហ្វ្រិ-កាំងក៏នាំអាឡាដាំងទៅលេងឯទីក្រុង ត្រង់កន្លែងដែលមានប្រជាជនកុះករច្រើន, ពិសេសគឺនៅកន្លែងដែលមានហាងលក់ទំនិញធំ១ របស់មហាពាណិជ ។ លុះចូលទៅដល់វិថីដែលមានហាងទំនិញធំ១ តាំងនៅត្រៀបត្រា គាត់ក៏និយាយទៅអាឡាដាំងថា "ឯងមុខជានឹងទៅជាពាណិជមួយដូចគេទាំងអស់គ្នា ដែលឯងបានឃើញនេះដែរ ។ ដូច្នេះ

គួរក្មួយឯងចូលទៅលេងជាមួយអ្នកទាំងអស់នេះផង, ដើម្បីឱ្យបានស្គាល់គ្នា" ។ មេធ្មប់បាននាំអាឡាដាំងទៅមើលព្រះវិហារ ដែលល្អហើយធំដាច់គេនៅក្នុងក្រុងនោះ, នាំចូលទៅក្នុងកន្លែងសំណាក់នៃពួកពាណិជបរទេស, ចូលទៅក្នុងព្រះបរមរាជវាំង នៃព្រះបាទស៊ុលតង់ ដែលកាលជំនាន់នោះគេអាចចូលបានដោយសេរី ។ លុះបានដើរមើលទីក្រុងសព្វគ្រប់ហើយ ជនទាំងពីរនាក់ក៏នាំគ្នាចូលទៅនៅក្នុងបន្ទប់មួយ នៃផ្ទះសម្រាប់ឈប់សម្រាក។ មេធ្មប់បានឃើញពាណិជជាច្រើនដែលគាត់ធ្លាប់បានស្គាល់គ្នាបន្តិចៗ ហើយតាំងពីគាត់ទើបនឹងមកដល់ទីក្រុងនេះម្ល៉េះ ។ មេធ្មប់ក៏រៀបចំជប់លៀងពាណិជទាំងនោះយ៉ាងសប្បាយ ព្រមទាំងបង្ហាញក្មួយគាត់ឱ្យជនទាំងនោះស្គាល់ទៀតផង ។ គេអាស្រ័យអាហារហើយស្រេចនៅពេលជិតយប់ ។ អាឡាដាំងចង់ជម្រាបលាមាវា ដើម្បីត្រឡប់ទៅផ្ទះវិញណាស់, ប៉ុន្តែមេធ្មប់អាហ្វ្រិកាំងមិនព្រមអនុញ្ញាតឱ្យអាឡាដាំងទៅតែម្នាក់ឯងទេ។ គាត់ជូនយុវជនរហូតទៅដល់ផ្ទះវិញ ។ ពោលពីម្តាយអាឡាដាំងវិញ កាលគាត់បានឃើញកូនស្លៀកពាក់យ៉ាងស្អាតបាតដូច្នេះ ក៏ត្រេកអរស្ទើររកអ្វីប្រៀបគ្មាន ។ គាត់និយាយជូនពរសព្វសាធុការមួយពាន់មួយម៉ឺនយ៉ាងដល់លោកមេធ្មប់នេះស្ទើរពុំដាច់ពីមាត់ ហើយគាត់ពោលថា "បងប្អូនប្រកបដោយធម៌ !!! ខ្ញុំមិនដឹងរកអ្វីក្រៅពីអរគុណ ចំពោះសេចក្តីសប្បុរសរបស់អ្នកនេះបានសោះ ។ ខ្ញុំយល់ច្បាស់ថា កូនខ្ញុំមិនសម នឹងទទួល



សារប្រយោជន៍ដែលអ្នកបានធ្វើដល់វានោះទេ ហើយវាមុខជាពុំអាចថែរក្សាទ្រព្យនេះបានឡើយ បើសិនជាវាខ្វះធម៌កតញ្ញូ ធ្វេសប្រហែសមិនព្រមគោរពដល់ឆន្ទៈ ដ៏ល្អដែលអ្នកនឹងប្រគល់ឱ្យ នូវគ្រឹះស្ថានមួយយ៉ាងសំខាន់ ។ ចំណែកខ្លួនខ្ញុំ, ខ្ញុំសូមសម្តែងអំណរគុណដ៏ជ្រាលជ្រៅចំពោះអ្នកម្តងទៀត ហើយខ្ញុំសុំឱ្យអ្នកមានអាយុយឺនយូរបន្តិច ដើម្បីនឹងបានឃើញកូនខ្ញុំធ្វើសេចក្តីកតញ្ញូស្នងចំពោះអ្នកវិញ ដែលគ្មានអ្វីក្រៅពីថែទាំរបស់ទាំងនោះឱ្យគង់វង្សតាមដំបូន្មានរបស់អ្នក" ។

មេធ្មប់អាហ្វ្រិកាំងក៏ឆ្លើយភ្លាមឡើងថា អាឡាដាំងជាក្មេងល្អចេះស្តាប់បង្គាប់ខ្ញុំគ្រាន់បើហើយ ខ្ញុំជឿជាក់ថា យើងនឹងអាចទទួលផលល្អអំពីវាខ្លះពុំខាន ។ តែខ្ញុំមានសេចក្តីតូចចិត្តបន្តិច ដោយពុំបានធ្វើការនេះឱ្យបានទាន់ពេលដូចសន្យា ព្រោះស្អែកនេះជាថ្ងៃសុក្របហាងទាំងអស់ត្រូវបិទទ្វារ ។ ដូច្នេះខ្ញុំពុំអាចដើររកជួលហាង និងទិញរបស់របរមកដាក់បានឡើយ នៅពេលដែលអ្នកជំនួញ កំពុងតែលេងសើចសប្បាយ ។ ដូច្នេះការនេះយើងលើកទៅធ្វើថ្ងៃសៅរ៍វិញ, ប៉ុន្តែស្អែកខ្ញុំនឹងមកយកអាឡាដាំងទៅដើរលេងនៅក្នុងសួនឧទ្យានមួយ ដែលអ្នកមានធំៗក្នុងប្រទេសធ្លាប់តែទៅលេងនៅកន្លែងនោះ។ ប្រហែលជាអាឡាដាំងវាពុំទាន់បានស្គាល់ការសប្បាយនៅកន្លែងនោះទេមើលទៅ ព្រោះតាំងពីដើមរហូតមកពេលឥឡូវ អាឡាដាំងធ្លាប់ស្គាល់តែក្មេង។ ពេលនេះ ខ្ញុំនឹងនាំវាឱ្យទៅស្គាល់មនុស្សចាស់ៗម្តង។ ពោលតែប៉ុណ្ណេះ

មេធ្មប់អាហ្វ្រិកាំងក៏លាប្រពន្ធនិងកូនមុស្តាហ្វាចេញទៅ ។ ចំណែកអាឡាដាំងដែលមានចិត្តសប្បាយ ស្រាប់ពីមុនមកដោយបានស្លៀកពាក់យ៉ាងស្អាតបាត ក៏រឹតតែមានសេចក្តីសប្បាយទុកជាមុនយ៉ាងខ្លាំងទៀត ។ ក្នុងការដើរលេងតាមសួនច្បារជិតៗទីក្រុងដូច្នេះ, ព្រោះអាឡាដាំងពុំដែលបានចេញក្រៅទីក្រុង, ពុំដែលបានឃើញកន្លែងជិតៗក្រុង ដែលជាទីមនោរម្យសប្បាយយ៉ាងក្រៃលែង ។

ស្អែកឡើង, អាឡាដាំងក្រោកពីគេងពីព្រលឹមរួចស្លៀកពាក់ហើយស្រេច បម្រុងនឹងចេញទៅភ្លាម ។ នៅពេលដែលមាគេមកនាំយកទៅដើរលេង ។ លុះចាំយូរៗទៅ មិនឃើញមាវាមកសោះវាក៏ស្ទុះទៅបើកទ្វារឆ្លេឆ្លាដូចមាន់រកពង រួចចេញទៅអង្គុយនៅមាត់ទ្វារដើម្បីរង់ចាំមើល តើគាត់មកឬទេ? ។ លុះក្រឡេកឃើញលោកមេធ្មប់ភ្លាមអាឡាដាំងក៏ស្រែកប្រាប់ម្តាយភ្លាម ។ រួចនិយាយលាម្តាយ, ទាញទ្វារបិទយ៉ាងរហ័សរត់សំដៅទៅរកមេធ្មប់ ។

មេធ្មប់អាហ្វ្រិកកាំងកាលបើបានឃើញអាឡាដាំង ក៏និយាយរាក់ទាក់ សម្តែងសេចក្តីស្និទ្ធស្នាលជាច្រើនបំផុត រួចពោលដោយញញឹមថា : “មកយើងទៅកូនប្រុស ថ្ងៃនេះមានាំក្មួយឯងទៅមើលអច្ឆរិយ-វត្ថុផ្សេងៗ” ។ មេធ្មប់ក៏នាំក្មួយចេញតាមមាត់ទ្វារមួយតម្រង់ទៅគេហដ្ឋានធំៗ ហើយល្អៗ ឬមួយក៏ទៅមើលប្រាសាទល្អឆើតៗ ដែលកន្លែងនីមួយៗ សុទ្ធតែមានសួនច្បារល្អៗ ហើយមានផ្លូវចេញចូលបាន



តាមចិត្តផង ។ នៅគ្រប់ប្រាសាទដែលគាត់ជួប គាត់តែងសួរអាឡា-ដាំងថា តើប្រាសាទនេះល្អឬទេ? ចំណែកអាឡាដាំងកំពុងតែគិតឆ្លើយស្រាប់តែទៅដល់ប្រាសាទមួយទៀត បុរសកំលោះក៏និយាយឡើងថា : “លោកមា !! ប្រាសាទនេះទើបល្អឆើតជាងប្រាសាទឯទៀតទាំងអស់ដែលយើងទើបនឹងឃើញ” ។ នៅពេលនោះ ជនទាំងពីរនេះចេះតែដើរទៅមុខ ដរាបលុះត្រាទៅដល់តំបន់ស្រុកស្រែ ។ មេធ្មប់បោកប្រាស់ដែលមានបំណងដើរទៅឆ្ងាយ ដើម្បីបំពេញសេចក្តីប្រាថ្នារបស់ខ្លួនក៏ឆ្លៀតឱកាសក្នុងពេលនោះ ចូលទៅក្នុងសួនច្បារមួយ ។ គាត់ក៏អង្គុយជិតអាងទឹកមួយ ដែលមានទឹកហូរចេញមកពីមាត់សិង្ហធ្វើពីទង់ដែង រួចធ្វើពុតជាអស់កម្លាំង ដើម្បីឱ្យអាឡាដាំងឈប់សម្រាក ។ បន្ទាប់មកគាត់ក៏និយាយទៅកាន់បុរសកំលោះថា : “ក្មួយ, ក្មួយឯងមុខជាអស់កម្លាំងជាងមា ត្រូវយើងឈប់សម្រាកនៅកន្លែងនេះសិនហើយ ដើម្បីឱ្យមានកម្លាំងនឹងដើរទៅទៀត ។ យើងត្រូវមានសេចក្តីក្លាហានជាច្រើនទៀត ដើម្បីនឹងបន្តការដើរលេងរបស់យើងនេះ” ។

លុះជនអ្នកដើរកំសាន្ត ទាំងពីរនាក់អង្គុយស៊ប់ស្រួលហើយបុរសមានវ័យចំណាស់ទាញយកសំពាយមួយ ដែលចងជាប់នឹងខ្សែក្រវាត់គាត់ ហើយដែលមាននំចំណី នឹងផ្លែឈើគ្រប់មុខសម្រាប់បរិ-ភោគ្គា ។ គាត់លាកញ្ចប់នំដាក់លើមាត់អាង ចែកគ្នាអាស្រ័យពាក់កណ្តាលម្នាក់ ។ ចំណែកផ្លែឈើគាត់បើកសេរីភាពឱ្យអាឡាដាំងរើស

យកបរិភោគតាមបំណង ។ នៅពេលអាស្រ័យអាហារនេះ ជរាជនមានវាចាទៅកាន់ក្មួយជាពាក្យប្រៀនប្រដៅៈហើយដែលជាកលឧបាយទាញអាឡាដាំងឱ្យងាកចេញពីការទៅលេងជាមួយក្មេងៗ ហើយត្រឡប់មកសេពគប់ជាមួយនឹងមនុស្សចាស់ស្លូតត្រង់ ប្រកបដោយគតិបណ្ឌិតវិញ ហើយឱ្យពិភាក្សាតែជាមួយជនខាងក្រោយនេះ ។ ដូច្នេះអ្នកនឹងទៅដូចជាជនទាំងនោះភ្លាម គឺមានទម្លាប់ពោលតែពាក្យថ្លៃថ្នូរ ពាក្យមានប្រយោជន៍” ។ លុះបរិភោគហើយស្រេចកាលណាជនទាំងពីរក៏ក្រោកឡើងដើរកាត់សួនច្បារ ដែលមានស្នាមភ្លោះតូចៗនៅខណ្ឌជាគ្រឿងសម្គាល់ព្រំដែនសួន ប៉ុន្តែគ្មានឧបស័គ្គអ្វីក្នុងការឆ្លងកាត់ឡើយ។ ការពិតគ្រាន់តែថា ពលរដ្ឋក្នុងប្រទេសនេះ ចេះសាមគ្គីរក្សាការពារគ្នា ដើម្បីកុំឱ្យកើតជម្លោះទាស់ទែងខ្វែងគំនិតគ្នាឡើយ ។ បន្តិចម្តងៗមេធ្មប់អាហ្វ្រិកាំងនាំអាឡាដាំងចេញទៅឆ្ងាយ ពីសួនច្បារដើរឆ្លងកាត់ជនបទផ្សេងៗ លុះត្រាតែជិតទៅដល់ព្រៃភ្នំក្រំថ្ម ។

អាឡាដាំង ដែលមិនធ្លាប់ធ្វើដំណើរឆ្ងាយដូច្នេះ ក៏អស់កម្លាំងទោរទន់ទាំងខ្លួន ទើបសួរទៅមេធ្មប់ថាៈ “លោកមា ! យើងទៅឯណាហ្នឹង? យើងបានទៅឆ្ងាយផុតពីសួនច្បារណាស់ហើយៗ ពេលនេះខ្ញុំឃើញតែភ្នំធំធេង ។ បើយើងនៅតែដើរទៅមុខទៀត ខ្ញុំមិនដឹងជាមានកម្លាំងអាចត្រឡប់មកដល់ទីក្រុងវិញបានទេ” - មេធ្មប់ក្លែងក្លាយក៏ឆ្លើយតបវិញថាៈ “ត្រូវមានសេចក្តីក្លាហានឡើងក្មួយប្រុស មាចង់នាំ



ឯងទៅមើលសួនច្បារមួយទៀត ដែលមានលម្អលើសលប់ ជាងសួនច្បារឯទៀតទាំងអស់ដែលអ្នកបានឃើញ ។ សួនច្បារនោះមិនមែននៅឆ្ងាយប៉ុន្មានទេ តែមួយជំហានទៀតដល់ហើយ ។ រួចកាលណាយើងទៅជិតដល់ ក្មួយឯងកុំភ្លេចនិយាយប្រាប់មាឱ្យសោះថា តើអ្នកស្តាយទេ បើសិនជាអ្នកមិនបានឃើញសួនច្បារនេះ” ។ អាឡាដាំងក៏ជឿតាមស្លុង មេធ្មប់ក៏នាំដើរទៅឆ្ងាយក្រៃលែង តែគាត់ចេះតែរករឿងនិយាយកំប្លែងលេង ដើម្បីកុំឱ្យស្វាត់ពេក កុំឱ្យអស់កម្លាំងខ្លាំងទៀតផង ។

ក្រោយមក អ្នកដំណើរទាំងពីរក៏ទៅដល់ចន្លោះភ្នំពីរ ដែលមានកម្ពស់ខ្ពស់ល្មម ហើយប្រហែលៗគ្នា ។ ច្រកភ្នំនោះមានទំហំមិនវែងប៉ុន្មានទេ ។ គឺនៅកន្លែងនេះហើយ ដែលមេធ្មប់អាហ្វ្រិកាំងចង់នាំអាឡាដាំងមក ដើម្បីនឹងបំពេញបំណងរបស់គាត់ ដែលគាត់បានខំកាត់មកតាំងពីចុងទ្វីបអាហ្វ្រិក រហូតមកដល់ប្រទេសចិននេះ។ ពេលនោះគាត់ក៏និយាយទៅកាន់អាឡាដាំងថា : “យើងកុំបាច់ទៅឆ្ងាយទៀតមាចង់បង្ហាញវត្ថុចម្លែកមួយឱ្យក្មួយឯងឃើញ ហើយវត្ថុនេះមនុស្សលោកទាំងអស់ពុំដែលស្គាល់ឡើយ ។ កាលបើឯងបានឃើញរបស់នោះអ្នកនឹងអរគុណមាដោយបានបង្ហាញរបស់នេះ ដែលមនុស្សក្នុងលោកគ្មានបានឃើញដូចក្មួយឯងទេ ។ ប៉ុន្តែនៅពេលដែលមាគូសភ្លើង ចូរឯងប្រមូលសម្រាមស្ងួតៗដែលនៅជិតដើម្បីបង្កាត់ភ្លើង” ។

នៅពេលដែលមេធ្មប់គូសភ្លើងភ្លាម អាឡាដាំងបានប្រមូលសម្រាមមួយគំនរធំប្រើការមិនអស់ គាត់ក៏ដុតភ្លើត ។ នៅពេលដែលភ្លើងកំពុងតែឆេះមេធ្មប់អាហ្វ្រិកាំងក៏ជះទឹកអប់ទៅលើ បណ្ដាលឱ្យភ្លើងឆេះឡើងសន្ធោសន្ធៅ ។ គាត់ក៏ដើរក្រឡឹងជុំវិញ ព្រមទាំងសូត្រមន្តអាគមទៀតផង. តែអាឡាដាំងឥតស្ដាប់បានបន្តិចឡើយ ។ ខណៈនោះស្រាប់តែញ័រកក្រើកព្រះធរណី រួចត្រង់កន្លែងភ្លើងនោះស្រាប់តែលេចចេញប្រហោងខ្វងមួយ នៅមុខមេធ្មប់និងអាឡាដាំងធ្វើឱ្យឃើញថ្មមួយដុំធំមានរាងបួនជ្រុងស្មើដាក់ផ្ដេកក្នុងនោះ ។ ក្នុងមួយជ្រុងប្រវែងប្រហែលមួយជំហានកន្លះ កម្ពស់ប្រហែលមួយជំហាន ។ នៅកណ្ដាលថ្មនោះមានភ្ជួរជាប់ក្រវិលមួយ ធ្វើអំពីទង់ដែងសម្រាប់កាន់លើកដុំសិលានោះ ។ អាឡាដាំងភ័យញ័រ នឹងព្រឹត្តិការណ៍ចម្លែកនេះ ក៏ចង់គេចវេះចេញ ។ ប៉ុន្តែជាការចាំបាច់មេធ្មប់ក៏ចាប់ហើយ ស្រែកគំហកឱ្យយ៉ាងខ្លាំង ព្រមទាំងទះមួយដៃថែមទៀត ធ្វើឱ្យអាឡាដាំងដួលផ្កាប់មុខទៅនឹងដី តែសំណាងល្អវាមិនបាក់ធ្មេញ គ្រាន់តែបណ្ដាលឱ្យលោហិតហូរចេញមករហាម ។ កុមារកម្សត់ញាប់ញ័រអស់សព្វសពាង្គកាយ ក៏ស្រែកទ្រហោយំឡើងថា : “លោកមា !!! តើខ្ញុំ មានទោសកំហុសអ្វីបានជាលោកមាធ្វើបាបខ្ញុំដល់ម្ល៉េះ? ជនប្រើកម្លាំងបាយក៏កំញើញថា “អញស្គាល់ហេតុបានជាអញធ្វើ អញជាមាឯង ហើយក្នុងបច្ចុប្បន្ននេះ ស្ទើទីជាឪពុកឯងផង ឯងមិនត្រូវតមាត់នឹងអញឡើយ ។



ប៉ុន្តែកូនប្រុស ចូរឯងកុំខ្លាចអ្វីឡើយ មាគ្មានត្រូវការសួរអ្វីឯងទេ ឯងគ្រាន់តែស្ដាប់មាប៉ុណ្ណឹងបានហើយ បើឯងចង់បានរបស់ដែលមាចង់ឱ្យឯងនោះ” ។ កិច្ចសន្ទនាដ៏សំខាន់នេះ បានធ្វើឱ្យអាឡាដាំងអន់តក់ស្លុតបន្តិច ។ លុះឃើញក្មេងកម្សត់មានស្មារតីនឹងនរឡើងវិញ ហើយមេធ្មប់ក៏បញ្ចេញវាចាឡើងថា : “តើក្មួយឯងបានឃើញទេ ដោយគុណធម៌នឹងដោយមន្តដែលមាធ្វើអម្បាញ់មិញនេះ ក៏បានកើតឡើងជាព្រឹត្តិការណ៍ផ្សេងៗ ។ ឥឡូវនេះចូរក្មួយឯងដឹងឱ្យហើយទៅថានៅក្រោមដុំសិលានេះ មានឃ្លាំងសម្ងាត់មួយដែលត្រូវបានក្មួយហើយអាចធ្វើឱ្យក្មួយឯងទៅជាអ្នកមានសម្បត្តិនៅថ្ងៃណាមួយ ។ គឺមានសម្បត្តិច្រើនជាងព្រះមហាក្សត្រសោយរាជ្យទាំងឡាយក្នុងពិភពលោកទៅទៀត ។ ការណ៍នេះពិតណាស់ គឺគ្មាននរណាមួយក្រៅពីក្មួយឯងហ៊ានពាល់ ឬលើកថ្មនេះ ដើម្បីចូលទៅខាងក្នុងបានឡើយទាំងខ្លួនមាសោតក៏ពុំហ៊ានពាល់ ឬលូកជើងទៅក្នុងឃ្លាំងនេះឡើយនៅ ពេលដែលឃ្លាំងនេះបើកចំហ ។ ហេតុដូច្នេះត្រូវក្មួយឯងប្រតិបត្តិការតាមពាក្យមាប្រាប់កុំឱ្យរអៀងវត្ថុបន្តិចឡើយ ។ ការណ៍នេះនឹងផ្ដល់លទ្ធផលដល់ខ្លួនឯង នឹងមាយ៉ាងច្រើនបំផុត ។

អាឡាដាំង ដែលពីដើមមានសេចក្ដីជឿងឆ្ងល់ក្រៃលែងនឹងព្រឹត្តិការណ៍ដ៏អស្ចារ្យនេះ លុះបានឮមេធ្មប់ពោលថា កំណប់ទ្រព្យនេះនឹងផ្ដល់ផលឱ្យខ្លួនរស់នៅដោយសប្បាយអស់មួយជីវិត ក៏ស្រាប់តែ

អរភ្លេចអស់រឿងអតីត ស្រែកសួរមេធ្មប់ភ្លាមថា : “លោកមា១រឿងនោះយ៉ាងម៉េច? ប្រាប់ខ្ញុំមក១ ខ្ញុំប្រុងតែនឹងទទួលធ្វើហើយមាអរណាស់១ ដែលក្មួយឯងព្រមទទួលធ្វើនាទីនេះ។ មេធ្មប់បន្លឺសម្លេងឡើង ព្រមទាំងឱបរឹតកុមារទៀតផង ។ ចូរក្មួយមកនេះ ចូលឱ្យជិតយកដៃកាន់ក្រវិលដែកនោះ រួចលើកទាញថ្មនេះឡើង ។ ប៉ុន្តែអាឡាដាំងក៏ឆ្លើយថា លោកមាខ្ញុំគ្មានកម្លាំងនឹងលើកម្នាក់ឯងរួចទេ ។ ដូច្នេះ មានតែមាឯងជួយខ្ញុំផង ។ ទេ, ពុំបាច់ត្រូវការឱ្យមាជួយទេ បើសិនជាមាជួយនោះយើងគ្មានបានផលអ្វីទាំងអស់ ត្រូវក្មួយឯងលើកម្នាក់ឯងទើបបាន ។ សូមក្មួយឯងគ្រាន់តែលើកដៃនឹកដល់គុណឪពុកនិងជីតាឯងប៉ុណ្ណោះ ហើយយកដៃកាន់ក្រវិលលើកឡើង នោះថ្មនឹងរបើកគ្មានលំបាកអ្វីទេ” ។ អាឡាដាំង ធ្វើតាមបង្គាប់មេធ្មប់ភ្លាម ថ្មក៏របើកដោយស្រួលមែន ។ បុរសជំទង់ក៏លើកថ្មនោះដាក់កន្លែងមួយ ។

លុះថ្មរបើកហើយ គេឃើញរូងមួយជម្រៅ៣ឬ៤ជំហាន មានទ្វារមួយ នឹងជណ្តើរសម្រាប់ចុះទៅខាងក្រោម។ មេធ្មប់ក៏ពោលឡើងថា: “កូនប្រុស ចូរឯងប្រុងផ្ទៀងស្តាប់មាឱ្យមែនទែននូវកិច្ចការ ដែលមានឹងនិយាយប្រាប់ដូចតទៅនេះ ។ ចូរឯងចុះទៅក្នុងរូងនេះ លុះឯងចុះទៅដល់កាំជណ្តើរថ្នាក់ក្រោមបង្អស់ ឯងឃើញទ្វារមួយចំហសម្រាប់ដើរទៅកាន់កន្លែងធំមួយ មានរាងជាអឌ្ឍមណ្ឌល ហើយខណ្ឌជាបីបន្ទប់ធំ១ ជាប់១គ្នា ។ នៅក្នុងបន្ទប់នីមួយ១ ខាងស្តាំនិងខាងឆ្វេងដៃ



អ្នកឃើញផើងធំ១ បួនធ្វើអំពីទង់ដែង មានមាសនឹងប្រាក់ពេញ ។ ប៉ុន្តែប្រយ័ត្នឱ្យមែនទែន ចូរឯងកុំពាល់ឱ្យសោះ ។ ហើយមុននឹងចូលទៅក្នុងបន្ទប់ទីមួយ ចូរអ្នកលាត់អាវអ្នក ហើយរឹបក្តោបឱ្យតឹងនឹងខ្លួនអ្នក ។ លុះចូរទៅដល់ខាងក្នុង ត្រូវឆ្លងទៅបន្ទប់ទីពីរ-ទីបី ភ្លាមកុំបីឈប់បង្អង់ឡើយ ។ គ្រប់កន្លែងទាំងអស់ ចូរប្រយ័ត្នកុំទៅជិតជញ្ជាំងឬធ្វើឱ្យប៉ះនឹងជាយអាវអ្នកព្រោះថា : បើអ្នកធ្វើប៉ះអ្នក នឹងស្លាប់មួយរំពេចនៅកន្លែងនោះ ។ ហេតុដូច្នេះហើយបានជាមាប្រាប់ថាឱ្យក្តោបអាវឱ្យតឹង ។ នៅចុងបន្ទប់ទីបី មានទ្វារមួយនាំផ្លូវចូលទៅកាន់សួនច្បារ ដែលមានដំដើមឈើជាច្រើនមានផ្លែសំយុងចុះរយោងរយាន។ រួចដើរឱ្យត្រង់ទៅមុខ កាត់តាមសួនច្បារដែលមាន ផ្លូវទៅកាន់ជណ្តើរដែលមានកាំហាសិបសម្រាប់ឡើងទៅកាន់ខឿនខាងលើ ។ កាលណាឯងឡើងទៅដល់លើខឿននោះហើយ ឯងនឹងឃើញនៅមុខអ្នកប្រហោងមួយនៅនឹងជញ្ជាំង ដែលគេចោះសម្រាប់តម្កល់អីវ៉ាន់ផ្សេង១ ។ នៅក្នុងប្រហោងនោះ មានចង្កៀងមួយអុជចោលនៅទីនោះ ។ ក្មួយឯងលូកដៃយករួចពន្លត់វាភ្លាម ។ បន្ទាប់មកក្រោយដែលឯងគ្រវាត់កន្ទុយប្រឆេះនិងចាក់ប្រេងចោលហើយ ឯងយកចង្កៀងនោះខ្ចប់ក្នុងអាវរួចយកមកឱ្យមា ។ ចូរឯងកុំខ្លាចខូចសម្លៀកបំពាក់ឱ្យសោះ ។ ប្រេងក្នុងចង្កៀងឥតធ្វើឱ្យប្រឡាក់ឯងទេ, ព្រោះកាលណាឯងចាក់ទឹកនោះចោលទៅ ចង្កៀងមុខជាស្ងួតថែសហើយ ។ ម៉្យាងទៀត បើ

សិនជាផ្លែឈើក្នុងសួននោះ ធ្វើឱ្យអ្នកចង់បរិភោគនោះ អ្នកអាចបេះយកមកបរិភោគបានតាមត្រូវការ ។ ត្រង់នេះឥតមានហាមឃាត់ទេ។

ពោលចប់តែប៉ុណ្ណេះភ្លាម មេធ្មប់អាហ្វ្រិកាំង ក៏ដោះយកចិញ្ចៀន ដែលពាក់ជាប់នៅនឹងម្រាមដៃគាត់បំពាក់ទៅនឹងម្រាមដៃអាឡាដាំង ដោយប្រាប់ថា នេះជារបស់សម្រាប់ការពារទៅនឹងគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតឡើង។ ក្រោយដែលបានពន្យល់ប្រាប់ហេតុផ្សេងៗ ជនប្រវ័ញ្ចក៏ពោលថា : "កូនប្រុស ! ទៅ ! ចុះទៅដោយស្រួល ! យើងម្នាក់ៗ នឹងទៅជាអ្នកមានអស់មួយជីវិត" ។

អាឡាដាំងចុះបន្តិចម្តងៗ ទៅក្នុងដី លុះដល់កាំក្រោមបំផុតក៏បានឃើញបន្ទប់បី ដែលមេធ្មប់បានព័ណ៌នាប្រាប់ខ្លួនមែន។ បុរសដើរឆ្លងកាត់ដោយសេចក្តីប្រយ័ត្នជាទីបំផុត បារម្ភខ្លាចស្លាប់ឥតអំពើ បើពុំបានប្រតិបត្តិតាមពាក្យបង្គាប់មេធ្មប់ ។ លុះចេញផុតបន្ទប់ទាំងបីនោះទៅ បុរសដើរឆ្លងកាត់សួនច្បារ ឡើងទៅលើខឿន លូកដៃចាប់យកចង្កៀង គ្រវែងប្រេះទៅដី និងចាក់ប្រេងចោលឈ្មូ, ចង្កៀងក៏ស្ងួតធេងដូចមេធ្មប់ពោលមែន ។ រួចមជ្ឈិមវ័យកុមារក៏ខ្ចប់ចង្កៀងនោះនឹងអាវ ចុះមកវិញភ្លាម, ឈប់កណ្តាលសួនច្បារ សម្លឹងរុក្ខផល្លា ដែលអ្នកបានឃើញតែនៅពេលដើរទៅ ។ រុក្ខជាតិនៃសួននេះ មានផ្លែចម្លែកអស្ចារ្យណាស់ ។ ដើមឈើនីមួយៗ មានផ្លែពណ៌ខុសគ្នាទាំងអស់ មានសរលោង, ភ្លឺចាំងដូចជាកែវចរណៃ, ក្រហម, ខៀវ, បៃតង



លឿងទុំ និងពណ៌ផ្សេងៗទៀតជាច្រើន ។ ហើយបណ្ដាដើមឈើទាំងនោះមានដើមឈើខ្លះផ្លែច្រើន ដើមឈើខ្លះផ្លែតិច ។ ផ្លែសគឺអង្កាំគជ់ខ្យង, ភ្លឺចាំងផ្លេកៗ គឺពេជ្រ, ក្រហមឆ្អៅគឺត្បូងទទឹម, ខ្លះទៀតក្រហមព្រឿងគឺត្បូងទទឹមពណ៌ខ្ចី, ខៀវខ្ចីគឺត្បូងមរកត, ខៀវសុទ្ធគឺត្បូងកណ្ដៀង, ស្វាយគឺត្បូងត្របែក (Améthyste) លឿងខ្ចីគឺជាត្បូងខៀវ (Saphir) ។ ហើយនៅមានផ្លែឯទៀតជាច្រើន ។ ការចម្លែកជាងគេគឺថា រុក្ខផលាទាំងនោះមានទំហំ នឹងលម្អប្លែកខុសពីផ្លែឈើទាំងអស់ ដែលគេពុំដែលឃើញមានដូចសោះក្នុងលោក ។ ដោយអាឡាដាំងជាក្មេងពុំដែលស្គាល់បាបបុណ្យគុណទោស និងតម្លៃជីវភាពមនុស្សដូចម្ដេច ក៏ឥតមានភ្ញាក់រលឹកនឹងការឃើញរុក្ខផលាដ៏អស្ចារ្យនេះសោះ គឺឥតធ្វើឱ្យវានឹកចង់ញ៉ាំមិនដូចជាផ្លែឈើឯទៀត ដែលមានពាសពេញនៅស្រុកចិន ដូចជាផ្លែទំពាំងបាយជូរសោះ ដែលអាឡាដាំងតែងតែត្រូវការជានិច្ច ។ ដូច្នេះ សឱ្យឃើញថា អាឡាដាំងមិនទាន់ដល់វ័យនឹងស្គាល់តម្លៃរបស់ទាំងនោះឡើយ ។ វានឹកស្មានថាផ្លែឈើទាំងអស់នោះជាកែវ ដែលគេលាបពណ៌ផ្សេងៗ ទេ, វាគ្មានតម្លៃអ្វីទាំងអស់ ។ ប៉ុន្តែដោយមើលទៅឃើញផ្លែឈើទាំងនោះ មានពណ៌ប្លែកគ្នាល្អៗ ហើយផ្លែនីមួយៗ មានលម្អ និងទំហំខុសគ្នាទាំងអស់បណ្ដាលឱ្យអាឡាដាំង មានចិត្តចង់បេះយកផ្លែឈើទាំងអស់នោះគ្រប់មុខ ។ វាក៏បេះយកផ្លែឈើគ្រប់ពណ៌ជាច្រើន ដាក់ក្នុងហោប៉ៅ អាវ



ផង ដាក់ក្នុងថង់ថ្មីៗពីរផង ដែលមេធ្មប់ទើបនឹងទិញឱ្យជាមួយគ្នានឹងសម្លៀកបំពាក់ ។ លុះដាក់ពេញហៅ្បរថង់ទាំងពីរហើយ, បុរសក៏ចងជុំវិញខ្សែក្រវាត់ ។ មិនតែប៉ុណ្ណោះ, ថែមទាំងញាត់នឹងផ្ទត់ខ្សែក្រវាត់ទៀត ដែលធ្វើអំពីកំណាត់សូតយ៉ាងធំ ហើយរុំជាច្រើនជុំផង ។ ប៉ុន្តែទីបំផុត បុរសលោភភ្លេច ពុំបានញាត់នៅជុំវិញខ្លួនគ្រប់ចន្លោះអាវទ្រនាប់ ។

អាឡាដាំង លុះបានបេះផ្លែឈើទាំងនោះអស់ហើយ ដោយពុំបានដឹងថា របស់ទាំងនោះមានប្រយោជន៍ដូចម្ដេចផង ក៏ដើររលះរលាំងកាត់បន្ទប់ទាំងបី ដើម្បីកុំឱ្យមេធ្មប់អាហ្វ្រិកាំងចាំយូរពេក ។ ក្រោយដែលបានដើរឆ្លងកន្លែងផ្សេងៗ យ៉ាងប្រយ័ត្នប្រយែងមក យុវជនក៏ឡើងមកដល់មាត់រូង ដែលមានមេធ្មប់អង្គុយនៅនោះ ។ លុះឃើញមេធ្មប់ភ្លាម អាឡាដាំងក៏ស្រែកឡើងថា : “លោកមាៗ ហុចដៃមកជួយលើកខ្ញុំឡើងផង” មេធ្មប់ក៏ឆ្លើយឡើងថា : “កូនប្រុសហុចចង្កៀងមកឱ្យមាមុន ចង្កៀងនេះដែលធ្វើឱ្យក្មួយឯងលំបាក” ។ សូមទោសលោកមា, អាឡាដាំងឆ្លើយ, ឥតទើសអ្វីនឹងចង្កៀងនេះទេ ខ្ញុំនឹងប្រគល់ជូនលោកមាដល់ខ្ញុំឡើងទៅដល់លើ ។ មេធ្មប់អាហ្វ្រិកាំងចង់ឱ្យអាឡាដាំងហុចចង្កៀងមកគាត់សិន មុននឹងវាឡើងចេញអំពីក្នុងដី ប៉ុន្តែអាឡាដាំងប្រកែកដាច់អហង្ការថា មិនព្រមឱ្យចាំវាឡើងមកដល់ខាងលើសិន ។ អស់សង្ឃឹម មេធ្មប់អាហ្វ្រិកាំងក៏ខឹងជា

ក្រៃលែងស្អុះទៅយកទឹកអប់ចាក់ទៅលើភ្លើង រួចតាំងសូត្រមន្តអាគមភ្លាម ។ ដុំសិលាក៏រំកិលទៅបិទមាត់រូងខ្លួនឯងជិតស្លុង ។ នៅលើកន្លែងនោះ ក៏មានដីពេញធម្មតា ដូចកាលពេលអាឡាដាំងនឹងមេធ្មប់ឃើញពីដំបូងនោះឯង ។

ដូច្នេះ ជាការពិតណាស់, មេធ្មប់អាហ្វ្រិកាំងនេះ មិនមែនត្រូវជាប្អូនមុស្តាហ្វា ឬជាមាអាឡាដាំងដូចវាបានពោលនោះឡើយ ។ វាជាជាតិអាហ្វ្រិកសុទ្ធៗ ហើយកើតនៅប្រទេសអាហ្វ្រិកទៀត ។ ប៉ុន្តែចូរយើងដឹងថា ដោយប្រទេសអាហ្វ្រិកជាប្រទេសមួយ មានអរិយធម៌ដ៏ខ្ពង់ខ្ពស់ខាងមន្តអាគម, បុរសនេះក៏បានរៀនវិជ្ជានេះតាំងតែពីកុមារភាព ។ លុះ ៤០ឆ្នាំក្រោយមក បន្ទាប់ពីបានរៀនវិជ្ជាមន្ត, វិជ្ជាទាយបែងភាគ, បំបាំងបាត់, ជ្រែកទឹក, ជ្រែកដី និងបានអានសៀវភៅមន្តផ្សេងៗ ចប់ជាច្រើន បុរសនោះក៏បានដឹងថា នៅក្នុងលោកនេះមានចង្កៀងទិព្វមួយ ។ បើនរណាមានចង្កៀងនេះ, អ្នកនោះឯងនឹងមានឫទ្ធិអំណាច មានទ្រព្យសម្បត្តិលើសលុបជាងស្តេចចក្រទៅទៀត ប៉ុន្តែលុះត្រាអ្នកនោះមានបុណ្យផង ទើបអាចទៅជាម្ចាស់វត្ថុនោះបាន ។ ក្រោយដែលបានប្រតិបត្តិវិជ្ជាទាយរួច, មេធ្មប់នេះដឹងច្បាស់ថា ចង្កៀងនេះស្ថិតនៅក្នុងរូងដី កណ្តាលអាណាចក្រចិន, ត្រង់កន្លែងដែលយើងទើបនឹងបានពោលមកខាងលើនេះ ។ ជឿជាក់ក្នុងចិត្តដូច្នេះហើយ ជនអ្នកស្វែងលាភនេះ ក៏ធ្វើដំណើរចេញពីប្រទេសអាហ្វ្រិកដូចយើង



បាននិទានរួចហើយ ។ ក្រោយដែលបានធ្វើដំណើរដ៏ឆ្ងាយហើយ ដោយលំបាកផង, គាត់ក៏បានមកដល់រាជធានី ដែលស្ថិតនៅជិតឃ្លាំងកំណប់ទ្រព្យនេះ ។ ប៉ុន្តែទោះបីគាត់ដឹងថា ចង្កៀងនៅត្រង់កន្លែងនោះក៏ដោយ, ក៏គាត់គ្មានអំណាចចូលទៅយកផ្ទាល់ខ្លួនឯងឡើយ ។ ហេតុដូច្នេះហើយបានជាគាត់ត្រូវការជនដទៃទៀត ឱ្យចុះទៅយកមកឱ្យគាត់ ។ ពេលនោះ គាត់ក៏បានជួបអាឡាដាំង ហើយនិយាយទៅអាឡាដាំង ដែលគាត់យល់ថា ជាក្មេងមិនដឹងខ្យល់អ្វីទាំងអស់ ហើយងាយនឹងសម្លុតវា ឱ្យបំពេញមុខការតាមគាត់ទៀតផង គឺថាក្រោយពេលដែលបានចង្កៀងនោះមកដល់ដៃគាត់ៗ នឹងសូត្រមន្តអាគមពីរម៉ាត់ ដូចគាត់បានធ្វើរួចមកហើយ ដើម្បីនឹងបំបាត់ខ្លួនអាឡាដាំងកុំឱ្យនរណាធ្វើជាសាក្សីដឹងឮទៀត ។ ការទះតប់, ការប្រើអំណាច ដែលមេធ្មប់ប្រព្រឹត្តទៅលើអាឡាដាំងទាំងប៉ុន្មាន គឺមានគោលបំណងតែមួយ គឺធ្វើឱ្យយុវជនមានទម្លាប់ខ្លាចគាត់ជរាប ដើម្បីដល់ពេលគាត់ត្រូវការចង្កៀងទិព្វនោះ អាឡាដាំងនឹងឱ្យភ្លាម ។ ប៉ុន្តែអំពើអកុសលតែងបានផលផ្ទុយទៅវិញ ។ ការនោះពុំបានសម្រេចដូចបំណងចិត្តគាត់សោះ ។ ដូច្នោះ, មេធ្មប់ក៏ប្រើអាការៈឃោរឃៅយង់ឃ្នងសាហាវជាក្រៃលែង ដើម្បីបំបាត់រូបអាឡាដាំងចោលដោយខ្លាចថា បើគាត់នៅតែចចេសជាមួយអាឡាដាំងតទៅទៀត ក្រែងមាននរណាគេស្តាប់ឮហើយផ្សាយដំណឹង ដែលគាត់ចង់លាក់ទុកឱ្យបាត់ស្ងាត់បំផុតនោះដល់គេឯងទៀតដឹង ។

មេធ្មប់លុះយល់ថា សេចក្តីសង្ឃឹមរបស់ខ្លួនត្រូវរលត់ត្រឹមនេះហើយ គាត់ក៏គ្មានផ្លូវអ្វីក្រៅអំពីត្រឡប់ទៅប្រទេសអាហ្វ្រិកវិញឡើយ ។ នៅថ្ងៃនោះឯង, គាត់ក៏ត្រឡប់ទៅស្រុកវិញមែន, គាត់ដើរត្រុកៗ ទៅតាមផ្លូវវាងឆ្ងាយ ដើម្បីកុំឱ្យចូលមកទីក្រុង ដែលគាត់បានចេញទៅជាមួយអាឡាដាំង ។ គាត់បារម្ភខ្លាចក្រែងអ្នកស្រុកសង្កេតឃើញថា ពីមុនគាត់ដើរជាមួយកូនក្មេងម្នាក់ ឥឡូវម៉េចក៏ត្រឡប់មកវិញតែម្នាក់ឯង ។

នៅគ្រប់កន្លែងទាំងអស់ មេធ្មប់លែងនឹកនាពីរឿងអាឡាដាំងឡើយ ។ គាត់នឹកថា អាឡាដាំងអស់រស់រានមានជីវិតទៀតហើយ ប៉ុន្តែគាត់ភ្លេចនឹកឃើញថា ខ្លួនគាត់បានបំពាក់ចិញ្ចៀនមួយនៅម្រាមដៃអាឡាដាំង ។ ចិញ្ចៀននោះ សម្រាប់ជួយយកអាសាកុមារនៅពេលមានអាសន្ន ។ ដូច្នោះ គឺមានតែចិញ្ចៀននេះហើយ ដែលអាចជួយយកអាសាអាឡាដាំងបាន តែអាឡាដាំងឥតស្គាល់តម្លៃគុណធម៌នៃចិញ្ចៀននោះឡើយ ។ តែគួរឱ្យឆ្ងល់ណាស់បាត់ចិញ្ចៀនផង, បាត់ចង្កៀងផង ម្តេចក៏មេធ្មប់នៅតែពុំទាន់អស់សង្ឃឹមទៀត។ នេះមកតែពីពួកមេធ្មប់ទាំងឡាយ ធ្លាប់ភពប្រទះនឹងបរាជ័យដូច្នេះជាច្រើនលើក ច្រើនគ្រាណាស់មកហើយ ។

អាឡាដាំងដោយពុំចាប់ភ្លឹកថា មេធ្មប់នឹងអាចមានចិត្តឃោរឃៅមកលើខ្លួនឡើយ ។ ព្រោះឃើញគាត់បានលួងលោមខ្លួន និងទិញ



ទ្រព្យសម្បត្តិឱ្យខ្លួនជាច្រើន ក៏នឹកថា គ្មានអ្វីប្រសើរក្រៅអំពីស្រែកហៅគាត់នោះទេ ។ ដូច្នោះហើយ បានជានៅពេលត្រូវគេកប់វាទាំងរស់, អាឡាដាំងខំស្រែកដង្ហោយហៅមាវាជាច្រើនដង ហើយពោលថាខ្លួននឹងប្រគល់ចង្កៀងនោះឱ្យគាត់ពុំខាន ។ ប៉ុន្តែសម្រែកនោះជាសម្រែកឥតចម្លើយ ជាសម្រែកគ្មានតម្លៃ គឺគ្មាននរណាអាចស្តាប់ឮឡើយ ។ បុរសក៏ត្រូវឋិតនៅក្នុងទីងងឹតឈឹងសូន្យ ។ បន្ទាប់មក, ក្រោយដែលខំទប់ទឹកភ្នែកកុំឱ្យរមៀលចេញមកម្តងៗ យុវជនកម្សត់ក៏ខំដើរពីមពាមចុះទៅដល់ថ្នាក់ក្រោមបង្អស់ នៃកាំជណ្តើរដើម្បីទៅរកកន្លែងភ្លឺនៅក្នុងសួនច្បារ ដែលខ្លួនទើបនឹងចេញមកអម្បាញ់មិញ ។ ប៉ុន្តែគួរឱ្យអាសូរកុមារណាស់ ទ្វារដែលបើកឡើង ដោយសារមន្តអាគមនោះ ក៏បិទជិតទៅវិញដោយសារ តែមន្តអាគមដែរទោះបុរសខំដើររាវទៅខាងមុខ ខាងឆ្វេង ខាងស្តាំជាច្រើនលើក ក៏ដោយ ក៏ឥតឃើញទ្វារសោះ ។ សម្រែកនឹងទឹកភ្នែកក៏ទ្វេឡើង, អ្នកកំលោះក៏អង្គុយលើកាំជណ្តើរ អស់សង្ឃឹមថា នឹងបានឃើញពន្លឺព្រះអាទិត្យទៀតឡើយ ហើយមុខជាស្លាប់នៅក្នុងទីនេះ តែឯកាអនាថាពុំខាន ។

អាឡាដាំង ឋិតនៅក្នុងសភាពដូច្នេះអស់ពេលពីរថ្ងៃ អត់ទឹកអត់បាយក្រហាយចិត្ត ។ នៅថ្ងៃទីបីដោយគិតឃើញថា សេចក្តីស្លាប់ចៀសពុំរួចហើយកុមារក៏លើកដៃទាំងពីរឡើង សំពះបួងសួងដល់គុណបុណ្យព្រះអាទិទេពដោយវាចាថា “គ្មានកម្លាំងនឹងឫទ្ធិឯណាពូកែជាងព្រះអាទិទេពទេ ដែលជាធំជាកំពូលលើលោកយើងនេះ” ។

ក្នុងការលើកដៃសំពះនេះ ដៃអាឡាដាំងក៏ប៉ះនឹងចិញ្ចៀនដែលមេធ្មប់បំពាក់ឱ្យ ហើយដែលអាឡាដាំងពុំទាន់ស្គាល់គុណធម៌នៃវត្ថុនេះនៅឡើយ ។ ពេលនោះ ស្រាប់តែឃើញអារក្សមួយមានមុខធំសម្បើម មានភ្នែកគួរឱ្យខ្លាចមានរូបរាងស្គមស្លេកហាក់ដូចជា ទើបនឹងងើបពីក្នុងដីមកៗឈរនៅមុខអាឡាដាំងហើយនិយាយថា :

តើលោកមានការអ្វី? ខ្ញុំមកនេះក្នុងឋានៈជាទាសី ដើម្បីទទួលបង្គាប់លោក និងអំពីជនទាំងឡាយឯណា ដែលមានចិញ្ចៀននេះនៅនឹងម្រាមដៃ ។ នៅមានអារក្សជាច្រើនទៀត ដែលមានភារៈដូចខ្ញុំដែរ ។ នៅគ្រប់ពេលគ្រប់ឱកាសទាំងអស់, អាឡាដាំងពុំដែលជួបប្រទះនឹងហេតុការណ៍ដូច្នេះសោះ បានជាការឃើញមុខអារក្សយ៉ាងសម្បើមនេះ ធ្វើឱ្យអាឡាដាំងភ័យភាំងស្ទើរបាត់ស្មារតីអស់ រកសម្ដីនិយាយគ្មាន ។ ប៉ុន្តែដោយយល់ការស្លាប់ធំជាងការតក់ស្លុតបុរសកម្សត់ក៏ខំតាំងស្មារតី ឆ្លើយយ៉ាងម៉ឺងម៉ាត់ឡើងថា : អ្នកជាអ្វី? បើអ្នកមានឫទ្ធិអំណាចមែន ចូរនាំខ្ញុំចេញពីកន្លែងនេះឡើង ។ គ្រាន់តែពោលប៉ុណ្ណេះពុំទាន់ផុតមាត់ផង ស្រាប់តែព្រះធរណីប្រេះបែកប្រហោង ។ អាឡាដាំងក៏បានមកដល់ខាងលើមាត់រូងមួយរំពេចត្រង់កន្លែងដែលមេធ្មប់បាននាំទៅ ។

គេពុំដែលឃើញអ្វីចម្លែក ដូចជាឃើញអាឡាដាំងក្នុងពេលនេះសោះ ។ វាទៅជាមឹងមាំងព្រោះវាឋិតនៅក្នុងទីដ៏ងងឹតអស់ពេលជាយូរ លុះឡើងមកដល់ទីភ្លឺ ភ្នែកវាក៏ចាំងរន្ទះពន្លឺរកមើលអ្វីពុំកើត ។



យុវជនខំទម្លាប់ភ្នែកនឹងពន្លឺថ្ងៃបន្តិចម្តងៗ រួចក្រឡេកមើលជុំវិញខ្លួនស្រាប់តែបាត់ប្រហោងរកមើលពុំឃើញឡើយ ។ គួរឱ្យឆ្ងល់ពន់ពេកណាស់, ឆ្ងល់ថា តើដែលខ្លួនបានឡើងមកដល់ខាងលើនេះ តើឡើងមកតាមរបៀបណា អីក៏ឆាប់ម្ល៉េះ ។ មានតែកំទេចផេះនៅសល់ទេដែល ធ្វើឱ្យអាឡាដាំងចំណាំកន្លែងរូងនោះបានបន្តិចៗ ។ បន្ទាប់មកងាកមុខឆ្ពោះទៅទីក្រុង កុមារក៏ឃើញទីក្រុងឋិតនៅកណ្តាលសួនច្បារទាំងឡាយ ស្គាល់ផ្លូវដែលមេធ្មប់នាំដើរមក ។ បុរសក៏ដើរតាមផ្លូវនោះដោយនឹកគុណពុំភ្លេច ចំពោះព្រះអាទិទេព ដែលធ្វើឱ្យខ្លួនបានឃើញលោកនេះម្តងទៀត ពីព្រោះពីមុនមកបុរសនឹកអស់សង្ឃឹមថា នឹងឡើងរួចពីទីងងឹតនោះហើយ ។ បុរសខំដើររហូតទៅដល់ទីក្រុងសំដៅទៅផ្ទះស្ទើរតែយោងខ្លួនឯងពុំរួច ។ ចូលទៅផ្ទះកាលណា, សេចក្តីសប្បាយនឹងឃើញភក្ត្រម្តាយក៏មានឡើង ប៉ុន្តែដោយការអស់កម្លាំងអត់អាហារមកជិតបីថ្ងៃហើយ បណ្តាលឱ្យបុរសដួលសន្លប់បាត់ស្មារតីអស់មួយសន្ទុះ ព្រោះបាក់ជ័របាយ ។ និទានពីម្តាយអាឡាដាំងដែលបានយំទួញសោក ជាច្រើនពេលមកហើយព្រោះបាត់កូន នឹកស្មានថាកូនខ្លួនមុខជាស្លាប់បាត់ទៅហើយ។ លុះឃើញកូនដួលដូច្នេះ ក៏ខំយកចិត្តទុកដាក់មើលថែរក្សាកូន លុះត្រាតែមានកម្លាំងពលំឡើងវិញ ។ បឋមវាចា ដែលអាឡាដាំង ពោលមានសេចក្តីដូច្នេះ “អ្នកម្តាយ ! កិច្ចដំបូងបង្អស់, ខ្ញុំសូមឱ្យអ្នកម្តាយរកបាយឱ្យខ្ញុំទទួលទានសិន, ម៉ែ

អើយបីថ្ងៃមកហើយ កូនឥតបានបរិភោគអ្វីបន្តិចបន្តួចសោះ" អ្នកស្រីមេម៉ាយក៏ទៅលើកយករបស់គ្រៀមគ្រោះ ដែលគាត់មានមកដាក់នៅខាងមុខកូន រួចពោលថា : "កូនប្រុសមាសម្ដាយ ! ចូរកូនញ៉ាំកុំបង្អំពេក, ព្រោះបរិភោគតាមឃ្លាន បណ្ដាលឱ្យមានគ្រោះថ្នាក់ជាខ្លាំង, ចូរកូន បរិភោគមួយៗកុំតាមចំណង់ ។ ហើយម្ដាយមិនចង់ឱ្យកូនឯងនិយាយរកម្ដាយភ្លាមទេ ។ កូនឯងនឹងមានពេលច្រើន ដើម្បីនិយាយរឿងរ៉ាវប្រាប់ម្ដាយ កាលណាកូនឯងមានកម្លាំងកំហែងស្រួលបួល ។ ម្ដាយអស់កើតទុក្ខទៀតហើយ ដោយបានឃើញកូនឯងម្ដងទៀតនេះ។ ទុក្ខសោករបស់ម្ដាយ កើតមានឡើងតាំងពីថ្ងៃសុក្រ ពេលដែលព្រះសុរិយាអស្ដង្គតទៅហើយ ពុំឃើញកូនឯងត្រឡប់មកផ្ទះវិញសោះ" ។

អាឡាដាំងក៏ស្ដាប់តាមដំបូន្មានម្ដាយ បុរសញ៉ាំមួយៗ ហើយយ៉ាងស្ងប់ស្ងៀម ហើយផឹកទឹកបន្តិចបន្តួច ។ លុះអាស្រ័យបាយរួច, អ្នកកំឡោះក៏ពោលទៅកាន់ម្ដាយថា : "អ្នកម្ដាយ, កូនមានទុក្ខទោសជាទម្ងន់ កើតមកអំពីអ្នកម្ដាយបានបណ្ដោយឱ្យកូនទៅតាមបុរសម្នាក់ដោយស្រួលដូច្នោះ ។ បុរសនោះ មានបំណងនឹងបំបាត់ជីវិតកូន ហើយនៅពេលដែលកូនកំពុងនិយាយនេះ បុរសនោះក៏កំពុងនឹកថា កូនចៀសពីសេចក្ដីស្លាប់ពុំរួចទេ ឬក៏នឹកថា កូនស្លាប់បាត់ទៅហើយ ស្លាប់តាំងពីថ្ងៃដំបូងម្ល៉េះ ។ អ្នកម្ដាយខំជឿថាគាត់ត្រូវជាមាខ្ញុំ ឯខ្ញុំជឿតាមអ្នកម្ដាយទៅដែរ ។ ដូច្នេះ តើយើងអាចយល់នូវចិត្តរបស់



មនុស្សដែលចេះនិយាយលួងលោម ផ្ដល់ទ្រព្យផ្ដល់សម្បត្តិ សន្យាថានឹងធ្វើនេះធ្វើនោះឱ្យយើងទេ? សូមអ្នកម្ដាយជ្រាបថា មេធ្មប់នេះ ជាមនុស្សក្បត់, មនុស្សកំណាច មនុស្សទុច្ចរិត ។ វាឱ្យទ្រព្យសម្បត្តិកូន, សន្យានឹងកូនគ្រប់បែបគ្រប់យ៉ាងៗនេះ គឺដើម្បីសម្រេចបំណងរបស់វា ដើម្បីបំបាត់ជីវិតកូន តែប៉ុណ្ណេះដោយប្រើកលឧបាយ ដូចកូនបាននិយាយជម្រាបអ្នកម្ដាយរួចទៅហើយ ។ ប៉ុន្តែខ្លួនអ្នកម្ដាយ ក៏ដោយខ្លួនកូនក៏ដោយ ឥតបានយល់ហេតុពីមុនបន្តិចសោះ ។ ចំណែកខ្ញុំៗ សូមបញ្ជាក់ថា ខ្ញុំឥតបានធ្វើអ្វីឱ្យផុលរមាស់ទាស់ដល់ចិត្តវាបន្តិចសោះ ។ អ្នកម្ដាយនឹងជ្រាបរឿងនេះច្បាស់ដោយខ្ញុំនឹងអធិប្បាយជូនតាំងពីខ្ញុំបែកពីអ្នកម្ដាយរហូតដល់មេធ្មប់បានបំពេញបំណងដ៏លាមកនេះ ។

អាឡាដាំងក៏ចាប់និយាយប្រាប់ម្ដាយ អំពីរឿងដែលកើតមានឡើងជាមួយមេធ្មប់ គឺតាំងពីថ្ងៃសុក្រ ដែលមេធ្មប់មកនាំទៅមើលវាំង មើលសួនច្បារ នៅខាងក្រៅព្រះរាជធានី និងអំពីរឿងផ្សេងៗ ដែលកើតមានឡើងនៅតាមផ្លូវ រហូតដល់ចន្លោះភ្នំ ដែលមេធ្មប់ត្រូវបំពេញបំណងវា ។ កុមារអធិប្បាយអំពីការ ដែលមេធ្មប់ចាក់ទឹកអប់ទៅលើភ្លើងហើយសូត្រមន្តអាគមបន្តិចផង ព្រះធរណីក៏បែកញែកមួយរំពេច ធ្វើឱ្យមានប្រហោងចុះទៅកាន់ឃ្លាំងមួយ ។ បុរសក៏ឥតភ្លេចនិយាយជម្រាបម្ដាយអំពីរឿងមេធ្មប់ទះតប់ខ្លួន ហើយបានបំពាក់ចិញ្ចៀនមួយឱ្យ ដើម្បីចុះទៅក្នុងរូងនោះ ។ ក្រោយមក, អាឡាដាំងនិទានអំពីការ

ដែលខ្លួនបានឃើញ នៅពេលដែលដើរឆ្លងចុះឡើង តាមបន្ទប់បី, ក្នុងសួនច្បារ, រួចឡើងទៅលើខឿន ដែលជាកន្លែងកុមារយកចង្កៀងទិព្វបាន ។ ខណៈនោះ, អាឡាដាំងក៏ទាញយកចង្កៀងពីក្នុងអាវ នឹងផ្លែឈើគ្រប់មុខគ្រប់ពណ៌ ដែលខ្លួនបានបេះនៅក្នុងសួនច្បារមកបង្ហាញម្ដាយ ។ ផ្លែឈើទាំងនេះសុទ្ធតែជាថ្មមានតម្លៃ ។ រស្មីភ្លឺត្រចះដូចជាព្រះអាទិត្យ, ដែលលេចចេញមកពីថ្មទាំងនោះ។ ដោយអំណាចចាំងនឹងពន្លឺចង្កៀង បានធ្វើឱ្យភ្លឺពេញក្នុងបន្ទប់, សឱ្យឃើញថារបស់នេះមានតម្លៃច្រើនណាស់ ។ ប៉ុន្តែម្ដាយអាឡាដាំង ក៏ពុំសូវស្រឡាញ់របស់នេះដូចជាកូនគាត់ដែរ គាត់មានអាកប្បកិរិយាជាធម្មតា ព្រោះប្ដីគាត់ពុំដែលមានរបស់ដូច្នេះឱ្យគាត់ទេ ។ មិនតែប៉ុណ្ណោះបណ្ដាបងប្អូនជិតខាងទាំងប៉ុន្មាន ក៏គាត់ពុំដែលឃើញមានពាក់ថ្មមានតម្លៃនេះដែរ ។ ដូច្នេះ មិនត្រូវឆ្ងល់ទេ ដែលស្រីមេម៉ាយយល់ថា របស់នេះជារបស់ពុំសូវមានតម្លៃ តែគ្រាន់ជាការល្អគន់ប៉ុណ្ណោះដោយសារមានពណ៌ប្លែកគ្នាច្រើន ។ អាឡាដាំងដាក់អច្ឆរិយវត្ថុទាំងនោះទៅលើខ្នើយក្រោមគ្រែវែងមួយដែលខ្លួនអង្គុយពីលើ ។ បន្ទាប់មក, កុមារបញ្ចប់រឿងដោយពោលថា : លុះខ្លួនត្រឡប់មកពីយកចង្កៀងវិញ ឡើងមកដល់មាត់រូងរៀបនឹងចេញ មាត់ទ្វាររូងក៏បិទជិតឈឹង ដោយអំណាចមន្តអាគមរបស់មេធ្មប់ ។ ការណ៍នេះកើតឡើងមកតែពីកុមារប្រកែកពុំព្រមឱ្យចង្កៀងនោះទៅមេធ្មប់ ។ មកដល់ត្រង់នេះ កុមារពុំអាច



និយាយតទៅទៀត ដោយឥតសម្រក់ទឹកភ្នែកបានឡើយ ព្រោះនឹកកម្សត់អំពីភាពរស់នៅដ៏វេទនាអំពីការគេកប់ខ្លួននៅក្នុងរូងទាំងរស់ដូច្នេះ ហើយដែលខ្លួនបានឡើងផុតពីទីនោះ គឺដោយសារតែខ្លួនធ្វើឱ្យប៉ះដៃនឹងចិញ្ចៀន ។ ប៉ុន្តែអាឡាដាំង នៅតែពុំទាន់ស្គាល់គុណភាពនៃចិញ្ចៀននេះនៅឡើយ ។ លុះចប់ រឿងនេះកាលណា, អាឡាដាំងក៏ពោលទៅកាន់ម្ដាយថា : “ការតមកទៀត ខ្ញុំពុំបាច់ជម្រាបទេ ព្រោះអ្នកម្ដាយដឹងហើយ ។ នេះជារឿងគ្រោះថ្នាក់របស់កូន ដែលបានពើបពះតាំងពីម្ដាយបាត់មុខខ្ញុំ” ។

ម្ដាយអាឡាដាំង ខំយកចិត្តទុកដាក់ស្ដាប់រឿងដ៏ចម្លែកនេះ ដោយឥតឆ្លើយកាត់ពាក្យកូនមួយម៉ាត់ឡើយ ហើយជាធម្មតារាល់តែមាតា គាត់តែងតែមានសេចក្ដីឈឺចាប់អាណិតកូនជាខ្លាំង ទោះបីកូនមានកំហុស ឬឥតកំហុសយ៉ាងណាក៏ដោយ ។ ប៉ុន្តែនៅកន្លែងខ្លះដែលធ្វើឱ្យគាត់ឆ្អន់ឆ្អាញ់ចិត្តពន់ពេក, គឺកន្លែងដែលពោលពីគំនិតអាក្រក់នៃមេធ្មប់, គាត់ក៏មានទឹកមុខខ្ញឹមជននោះក្រៃលែង ។ គាត់ជេរប្រទេចផ្ដាសាមេធ្មប់នោះរាប់ពុំអស់ ដូចពាក្យថា: “អាមនុស្សក្បត់ អាមនុស្សព្រៃ, អាមេចោរ មេបោកប្រាស អាជនបច្ចាមិត្ត, អាជនបំផ្លាញមនុស្សលោក ។ ពិតមែនហើយកូន, គាត់ពោលបន្ថែម វានេះជាមេធ្មប់ ហើយមេធ្មប់ទាំងឡាយសុទ្ធតែជាមេរបល់នៃប្រជាជាតិ ។ វានេះមានការទាក់ទងតែជាមួយខ្មោចបិសាច តាមស្នេហ៍តាមមន្ត

អាគម ។ ខ្ញុំសូមទទួលសាធុព្រះអាទិទេព ដែលពុំព្រមឱ្យការឃោរឃៅរបស់មេធ្មប់ធ្លាក់មកលើកូនឯងបាន ។ ត្រូវកូនឯងអរគុណនឹងមេត្តាធមិរបស់ព្រះអង្គនេះផង ។ កូនឯងពុំអាចចៀសពីសេចក្តីស្លាប់រួចទេ បើសិនជាកូនឯងពុំបាននឹកដល់គុណបុណ្យ ឬអង្វរសូមអាសាព្រះអាទិទេព" ។ ម្តាយកុមារក៏ពោលត្មះតិះដៀលមេធ្មប់តទៅទៀតជាច្រើន ដែលបានធ្វើឱ្យកូនគាត់វេទនា។ ប៉ុន្តែនៅពេលកំពុងនិយាយ គាត់ឃើញអាឡាដាំងកំពុងតែអង្គុយងោក ។ គាត់ក៏រៀបកន្លែងឱ្យកូនគាត់គេង ។ រួចបន្តិចមក គាត់ក៏ចូលនិទ្រាដែរទៅ ។

អាឡាដាំង ដែលពុំបានសម្រាកកម្លាំងបន្តិចសោះ ពេលដែលនៅក្នុងរូង ព្រោះភ័យតែខ្លាចស្លាប់ ក៏និទ្រាលក់ស្កប់ស្កល់តាំងពីព្រលប់ទល់ភ្លឺ។ លុះស្អែកឡើង ថ្ងៃរះកម្ពស់ណាកម្ពស់ណើទើបក្រោក។ ក្រោកឡើងភ្លាម, បុរសស្រែកទារបាយម្តាយបរិភោគ ម្តាយក៏មានសេចក្តីសប្បាយជាក្រៃលែង និងរៀបបាយឱ្យកូនអាស្រ័យ។ លុះរកបានហើយ ម្តាយក៏ពោលថា: "ឱកូនប្រុស ! ម្តាយមានតែនំបុ័ងមួយដុំនេះឱ្យកូនឯងបរិភោគ" ម្ហូបអាហារបន្តិចបន្តួចនៅក្នុងផ្ទះកូនឯងបរិភោគពីល្ងាចម្សិលមិញអស់ហើយ។ ចូរកូនឯងខំអត់ធ្មត់បន្តិចទៅ មិនយូរប៉ុន្មានទេ ម្តាយនឹងទៅរកបានឱ្យកូនឯងបរិភោគទៀត ។ ម្តាយនៅសល់អម្បោះរវៃខ្លះ, ម្តាយនឹងយកអម្បោះនោះទៅលក់ទិញនំបុ័ង និងអីវ៉ៃអីវ៉ាន់ខ្លះសម្រាប់ពេលបាយថ្ងៃត្រង់។ អាឡាដាំងក៏ឆ្លើយវិញ



ភ្លាមថា : "អ្នកម្តាយ ! សូមអ្នកម្តាយទុកអម្បោះនេះលក់ទៅថ្ងៃក្រោយ, ឥឡូវនេះ សូមអ្នកម្តាយឱ្យចង្កៀងដែលខ្ញុំជូនទៅអ្នកម្តាយពីម្សិលមិញមកខ្ញុំ ខ្ញុំនឹងយកចង្កៀងនេះទៅលក់។ ហើយប្រាក់ដែលលក់បានមក កូននឹងទៅទិញគ្រឿងបរិភោគពេលព្រឹក, ថ្ងៃត្រង់ និងល្ងាច"។ ម្តាយអាឡាដាំងក៏ទៅយកចង្កៀងដែលគាត់ទុកនោះមក រួចនិយាយថា : "នេះនែកូន ! តែដូចជាកខ្វក់បន្តិច ចាំម្តាយរកអីជូតឱ្យស្អាតសិន ក្រែងវាបានថ្លៃគ្រាន់បើបន្តិច"។ ម្តាយអាឡាដាំងក៏ទៅយកទឹកនិងដីខ្សាច់បន្តិចមកដុស។ ប៉ុន្តែនៅពេលដែលគាត់ចាប់ដុសចង្កៀងនោះភ្លាម ស្រាប់តែអារក្សមួយមានមុខគួរឱ្យខ្លាចមាន ទំហំធំស្កឹមស្កៃងើបឡើងសើងទ្រើងឈរ នៅមុខគាត់រួចនិយាយថា : "តើអ្នកស្រីមានការអ្វី? ខ្ញុំបាទមកនេះក្នុងឋានៈជាទាសី ដើម្បីទទួលបង្គាប់ពីអ្នកស្រីនឹងអំពីជនទាំងឡាយ ឯណាដែលមានចង្កៀងនេះនៅនឹងដៃមិនតែប៉ុណ្ណោះនៅមានទាសីជាច្រើនទៀតដែលមានភារៈដូចជាខ្ញុំប្របាទនេះដែរ"។

ម្តាយអាឡាដាំងឥតគិតរកអ្វីឆ្លើយបានឡើយចក្ខុគាត់ មិនអាចទ្រាំទ្រនឹងមុខអារក្ស ដែលអាក្រក់គួរឱ្យខ្លាចនេះឡើយ ។ គាត់ស្រៀវខ្លួនខ្ញាក១ ហើយក្បាលគាត់ដូចជារីកធំឡើង១ លុះត្រាតែគាត់ដួលសន្លប់បាត់ស្មារតី នៅពេលដែលអារក្សពោលពាក្យ ដំបូងមករកគាត់ ។

អាឡាដាំង ដែលធ្លាប់ពើបពះប្រទះការនេះម្តងរួចហើយ កាលនៅរូងដី ក៏ឥតបង្អង់ពេល ស្ទុះទៅស្រវាយកចង្កៀង រួចឆ្លើយទៅកាន់អារក្សនោះជំនួសម្តាយថា "ខ្ញុំឃ្លាន ! ចូរអ្នករកអ្វីមកឱ្យខ្ញុំទទួលទានបន្តិច" ។ ថាតែប៉ុណ្ណោះ អារក្សនោះក៏ថយខ្លួនបាត់ទៅ។ មួយសន្ទុះក្រោយមក ស្រាប់តែឃើញអារក្សទូលថាសប្រាក់មួយមានម្ហូប១២មុខ យ៉ាងឆ្ងាញ់អស្ចារ្យ ដាក់ក្នុងចានគ្របដែលធ្វើអំពីលោហធាតុដូចគ្នា មាននំប៉ុង ៦សដូចទឹកកក។ នៅលើចានទាំងនោះ មានដបស្រាទំពាំងបាយជូរពីរដប និងពែងពីរធ្វើអំពីប្រាក់សុទ្ធ។ លុះដាក់របស់នោះលើគ្រែវែងមួយស្រួលបួលហើយ អារក្សនោះក៏អន្តរធានបាត់ទៅ ។

ការណ៍នេះកន្លងទៅអស់ពេលជាយូរដែរហើយ គឺអារក្សបានមកម្តងទៀត ហើយបាត់ខ្លួនទៅទៀតហើយ ក៏ម្តាយអាឡាដាំងនៅតែពុំទាន់ដឹងខ្លួននៅឡើយ ។ អាឡាដាំងបានយកទឹកលាបមុខគាត់ជាច្រើនដង ដើម្បីធ្វើឱ្យគាត់មានស្មារតីឡើងវិញ តែគ្មានបានប្រយោជន៍អ្វីសោះ។ លុះក្រោយបន្តិចមក ដោយអំណាចម្ហូបទាំងនោះបានផ្សាយក្លិនពាសពេញ គាត់ក៏បានដឹងខ្លួននៅពេលនោះឡើង ។ អាឡាដាំងក៏និយាយទៅកាន់ម្តាយភ្លាមថា : "គ្មានការអ្វីទេអ្នកម្តាយ ! សូមអ្នកម្តាយក្រោកឡើងពិសាក្រយា ។ វត្ថុនេះហើយដែលធ្វើឱ្យអ្នកម្តាយសប្បាយចិត្ត ដែលត្រូវតាមចំណង់ឃ្លានរបស់ខ្ញុំ។ ចូរយើងកុំទុកម្ហូបឱ្យត្រជាក់ មកម៉ាក់ទទួលទានភ្លាមទៅ" ។



ម្តាយអាឡាដាំងមានសេចក្តីងឿងឆ្ងល់ជាក្រៃលែង កាលបើគាត់បានឃើញថាសធំមួយមានម្ហូប១២មុខ មាននំប៉ុង៦ មានស្រាពីរដប នឹងពែងពីរ ហើយម្ហូបទាំងនោះមានក្លិនក្រអូបឆ្ងាញ់គួរឱ្យស្រក់ទឹកមាត់ ។ ឃើញដូច្នេះគាត់ក៏សួរអាឡាដាំងភ្លាមថា : "កូន ! របស់ទាំងនេះបានមកពីណា? តើយើងត្រូវដឹងគុណនរណា ដែលមានចិត្តសប្បុរសដូច្នេះ? ព្រះបាទស៊ុលតង់ឬ? ដោយព្រះអង្គបានជ្រាបនូវទុក្ខយើង ហើយមានមេត្តាដល់យើងយ៉ាងនេះ?" អ្នកម្តាយ. អាឡាដាំងឆ្លើយ. "អញ្ជើញមកពិសាបាយសិន អ្នកម្តាយក៏មុខជាឃ្លានដូចខ្ញុំដែរ។ ឯរឿងអីៗ ដែលអ្នកម្តាយត្រូវការដឹងចាំយើងទទួលទានបាយរួចខ្ញុំនឹងនិយាយជម្រាប" ។ ម្តាយនិងកូនទាំងពីរនាក់ ក៏អាស្រ័យម្ហូបអាហារទាំងនោះដោយល្មោភជាទីបំផុត ព្រោះជនទាំងពីរនេះ ពុំដែលអាស្រ័យម្ហូបម្ហាយ៉ាងសម្បូរដូច្នេះសោះ ។

នៅពេលបរិភោគអាហារនេះ ម្តាយអាឡាដាំងឥតមាននឿយណាយនឹងមើលហើយសរសើរពុំដាច់មាត់ នូវថាសនិងចានទាំងឡាយនោះបីគាត់ពុំស្គាល់ថា តើវត្ថុទាំងនេះធ្វើអំពីប្រាក់សុទ្ធ ឬ អំពីលោហធាតុផ្សេងៗទៀតក៏ដោយ ឬពិតមែនតែគាត់ធ្លាប់បានឃើញរបស់ដូច្នេះជាញឹកញាប់ហើយក៏ដោយ។ និយាយឱ្យចំទៅ គឺថាគាត់ឥតទាំងស្គាល់តម្លៃរបស់នោះផង តែហេតុដែលទាញភ្នែកគាត់ឱ្យមើលហើយមើលទៀត គឺត្រង់របស់ទាំងនោះនៅថ្មីៗទាំងអស់។ សូម្បីតែ អាឡា-

ដាំងកូនគាត់ក៏ដោយ ក៏ពុំសូវស្គាល់តម្លៃរបស់នោះជាងគាត់ ប៉ុន្មានដែរ ។

អាឡាដាំងនឹងម្ដាយយល់ថា ការទទួលទានអាហារអម្បាញ់មិញនេះ គ្រាន់តែបន្តិចបន្តួចទេ ក៏បបួលគ្នាអង្គុយបរិភោគបាយពេលថ្ងៃត្រង់ទៀត ។ ម្ហូបយ៉ាងល្អៗធ្វើឱ្យជនទាំងនោះបរិភោគយ៉ាងឆ្ងាញ់បំផុត។ ដោយជនទាំងពីរកំពុងឃ្លានខ្លាំង, គេក៏សម្រេចថានឹងរួបរួមម្ហូបអាហារទាំងពេលថ្ងៃត្រង់ ល្ងាច បរិភោគតែមួយពេលនេះឱ្យស្រេចតែម្ដងទៅ កុំចាំបាច់បរិភោគម្ដងទៀតធ្វើអ្វី។ ពេលបាយរួមក៏បានហើយស្រេច។ ប៉ុន្តែនៅសល់ម្ហូបអាហារមិនត្រឹមតែគ្រាន់មួយពេលល្ងាចទៀតទេ គឺនៅសល់ពីរពេលទៀតយ៉ាងបរិបូណ៌ ។

ម្ដាយអាឡាដាំង លុះបានលើកចានក្បានចេញហើយនិងយកសាច់ ដែលឥតទាន់បានបរិភោគបន្តិចសោះនោះទៅទុក ក៏មកអង្គុយលើកៅអីវែងជិតកូនរួចនិយាយថា: “ម្ដាយប្រុងតែចាំស្ដាប់រឿងដែលកូនបានសន្យាថានឹងជម្រាបប្រាប់ម្ដាយ” ។ អាឡាដាំងក៏និយាយរៀបរាប់ប្រាប់ម្ដាយសព្វគ្រប់ អំពីរឿងហេតុដែលកើតមានឡើងជាមួយអារក្ស នៅពេលគាត់ដួលសន្លប់ រហូតដល់គាត់បានដឹងខ្លួនឡើងវិញ ។ ម្ដាយអាឡាដាំងនៅតែឆ្ងល់នឹងសុន្ទរវាចានៃកូនគាត់ នឹងការឃើញរូបអារក្សនោះណាស់ ក៏ចេះតែសួរដេញកូនគាត់ទៅទៀត : “ចុះកូនឯងនិយាយទៅរកអារក្សនោះដូចម្ដេចទៅ មិនដែលសោះហើយ តាំងពី



ម្ដាយកើតមកម្ដាយពុំដែលឮមនុស្សកើតជំនាន់ម្ដាយគេនិយាយថាបានឃើញរឿងរ៉ាវដូច្នេះឡើយ ។ ហើយដែលអារក្សនេះបង្ហាញខ្លួននៅមុខម្ដាយ តើដោយហេតុភេទអ្វី? ម្យ៉ាងទៀត, ចុះហេតុអ្វីបានជានិយាយមករកម្ដាយវិញ មិននិយាយទៅរកកូនឯង ព្រោះកូនឯងវាធ្លាប់បានឃើញនៅក្នុងរូងឃ្លាំងម្ដងរួចហើយ?” ។

អាឡាដាំងក៏ឆ្លើយសាសព្ទឡើងថា : “អ្នកម្ដាយ, អារក្សដែលមកបង្ហាញខ្លួននៅមុខអ្នកម្ដាយអម្បាញ់មិញនេះ, មិនមែនតួអារក្សដដែល ដែលមកបង្ហាញខ្លួនខ្ញុំពីមុននោះទេ ។ វាដូចគ្នាត្រង់កន្លែងខ្លះមែន ព្រោះវាមានមាឌធំសម្បើមដូចគ្នា, ប៉ុន្តែ ទឹកមុខនឹងសំលៀកបំពាក់ខុសគ្នាស្រឡះ ដូច្នេះអារក្សនោះក៏មានម្ចាស់ខុសគ្នាដែរ។ អារក្សដែលខ្ញុំឃើញពីមុននោះនិយាយថា វាជាទាសីនៃចិញ្ចៀនដែលខ្ញុំពាក់នៅម្រាមដៃ។ ឯអារក្សដែលម៉ាក់ទើបនឹងឃើញនេះពោលថា វាជាទាសីចង្កៀងដែលម៉ាក់កំពុងកាន់ ។ ប៉ុន្តែខ្ញុំជឿថា ម៉ាក់ឥតបានឮសំដីទាំងនេះទេ ព្រោះនៅពេលអារក្សនោះនិយាយ ម៉ាក់សន្លប់ឥតដឹងខ្លួនឡើយ” ។

“អូ ! បើដូច្នេះគឺមកពីចង្កៀងកូនឯងនេះហើយ បានជាអារក្សវានិយាយមករកម្ដាយ មិននិយាយទៅរកកូន? អើ! បើអីចឹងមែន ចូរកូនឯងយកចង្កៀងនេះចេញពីមុខពីមាត់ម្ដាយ ទៅដាក់ត្រង់កន្លែងណាដែលឯងពេញចិត្តចុះ ។ ម្ដាយលែងចង់ប៉ះពាល់ទៀតហើយ ។ ម្ដាយ